**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University Of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការយល់ដឹងគតិយុត្តលើសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចនៅកម្ពុជា៖ ករណីខេត្តក្រចេះ

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ **ក. ឈិន ចន្ទ័ក្រូចគ្គី**

**ក. កេង គីមឡេង**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាច់ ផល្លី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឈិន វភ័ក្ត្រវត្តី** និង **កេង គីមឡេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ១៩ ឆ្នាំសិក្សា ២០១៥-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

## សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកឪពុក អ្នកម្តាយ** ជាទីគោរពស្រឡាញ់ ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ផ្តល់កំលាំងចិត្ត និង ជួយទំនុកបំរុងកូនបានសិក្សា តាំងពីថ្នាក់បឋមសិក្សា រហូតដល់ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី ១៩ នេះ។

សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ប្រធានការិយាល័យ និងសាស្ត្រចារ្យគ្រប់មុខជំនាញទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ក្នុងការដឹកនាំ ពង្រឹងគុណភាពលើកកម្មវិធីសិក្សា និងបង្ហាត់បង្រៀនប្រកបដោយប្រសិទ្ធិភាពតាំងពីថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ការសិក្សា ជាពិសេសមានការលើកទឹកចិត្ត និងជម្រុញឲ្យនាងទាំងពីរទទួលបានពុទ្ធិដើម្បីជាស្ពាននាំទៅរកភាពជោគជ័យនាថ្ងៃអនាគត។

ជាពិសេស នាងខ្ញុំទាំងពីរសូមថ្លែងអំណរគុណចំពោះ **លោកបណ្ឌិត ហាប់ ផល្លី** ដែលជាសាស្ត្រចារ្យមួយរូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាសាស្ត្រាចារ្យណែនាំសារណានាងខ្ញុំទាំងពីរ ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំបង្ហាត់បង្រៀន និងផ្តល់នៅចំណេះដឹងដែលទាក់ទងនឹងសារណានេះ ព្រមទាំងជួយបំពេញចំនុចខ្វះខាត និងកែលម្អកំហុសឆ្គងរបស់នាងខ្ញុំទាំងពីរ។

ជាទីបញ្ចប់ នាងខ្ញុំទាំងពីរ សូមបួងសួងដល់ទេវតា និងវត្ថុស័ក្តិទាំងអស់ក្នុងលោក សូមជួយថែរក្សាឃុំគ្រង ដល់អ្នកមានគុណទាំងអស់ឲ្យជួបប្រទះតែសេចក្តីសុខចម្រើន សុខភាពបរិបូណ៌ ព្រមទាំងប្រកបការងារអ្វីៗឲ្យបានជោគជ័យប្រកបដោយឧត្តមភាព និងភាពថ្កុំថ្កើងជានិរន្តរ៍។

## អារម្ភកថា

ជាបឋម នាងខ្ញុំ ឈ្មោះ **ឈិន ចន្ទ័ក្រូចត្តី** និង **កេង គីមឡេង** សូមគោរព និងជម្រាបសួរដល់សាស្ត្រាចារ្យទាំងអស់ជាទីគោរព និងសូមស្វាគមន៍មិត្តនិស្សិតទាំងអស់ជាទីរាប់អាន។

ក្នុងនាមនាងខ្ញុំទាំងពីរបានកំពុងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ៤ឆ្នាំ កន្លងមក ខ្ញុំទាំងពីរបានក្រេបជញ្ជក់ ទទួលបានពុទ្ធិ ក៏ដូចជាទ្រឹស្តី បទពិសោធន៍ជាច្រើនទាក់ទងនឹងវិស័យច្បាប់ ក៏ដូចជាចំណេះដឹងទូទៅផ្សេងៗទៀតផងដែរ។

នាងខ្ញុំទាំងពីរបានមូលមតិគ្នាចងក្រង នូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញបត្រ ដែលក្រោមចំណងជើងថា " **ការយល់ដឹងគតិយុត្តិលើសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចនៅកម្ពុជា៖ ករណីខេត្តក្រចេះ** " ដោយការយល់ដឹងផ្នែកច្បាប់របស់បងប្អូនជនជាតិដើមភាគតិចនៅមានកម្រិត ក៏ដូចជាការទទួលព័ត៌មានមិនទាន់បានពេញលេញ អាចធ្វើឲ្យពួកគាត់ប្រើប្រាស់ដីមិនសមស្របច្បាប់ ក៏អាចធ្វើឲ្យជនទុច្ចរិក ឬ ឈ្មួញខិលខូចមានការរំលោភបំពានដីរបស់ពួកគាត់។

ទោះបីជាយ៉ាងណា ដោយសារចំណេះដឹង និងបទពិសោធន៍ក្នុងការសិក្សាស្រាវជ្រាវនៅមានកម្រិត ក៏ដោយសារជួបប្រទះបញ្ហាកខ្វះខាតផ្នែកឯកសារ ហើយនេះក៏ជាស្នាដៃដំបូងរបស់នាងខ្ញុំទាំងពីរផងដែរ ដូច្នេះសារណានេះពិតមានភាពខ្វះចន្លោះជៀសមិនផុត។ នាងខ្ញុំសូមខន្តីអភ័យទោសទុកជាមុនដែរ ចំពោះកំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនាក្នុងសារណានេះ នាងខ្ញុំទាំងពីររង់ចាំទទួលមតិរិះគន់បែបស្ថាបនាពីសំណាក់សាស្ត្រាចារ្យ មិត្តអ្នកអាន សិស្សនិស្សិត ដើម្បីធ្វើឲ្យសារណានេះកាន់តែប្រសើរ។

# មាតិកា

**សេចក្ដីផ្ដើម** ........ ១

## ជំពូកទី១
## សញ្ញាណទូទៅនៃជនជាតិដើមភាគតិចនៅកម្ពុជា

**១.១.ដើមកំណើតនៃជនជាតិដើមភាគតិច** ........ ៣

១.១.១.អត្តសញ្ញាណ ........ ៥

១.១.២. ស្ថានភាពជីវភាពរស់នៅ ........ ៧

១.១.៣.វប្បធម៌ ប្រពៃណី និងការអប់រំ ........ ៧

**១.២.ទីតាំងភូមិសាស្ត្ររបស់ជនជាតិដើមភាគតិចនៅកម្ពុជា** ........ ៨

**១.៣.បទដ្ឋានគតិយុត្តជាតិដែលអនុវត្តចំពោះជនជាតិដើមភាគតិច** ........ ៩

១.៣.១.រដ្ឋធម្មនុញ្ញ ........ ៩

១.៣.២.ច្បាប់ភូមិបាល ........ ៩

១.៣.៣.ច្បាប់ព្រៃឈើ ........ ១០

១.៣.៤.ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ........ ១១

១.៣.៥.គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ........ ១២

១.៣.៦.គោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច ........ ១២

## ជំពូកទី២
## ការយល់ដឹងគតិយុត្តលើសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ខេត្តក្រចេះ

**២.១.ទិដ្ឋភាពទូទៅនៃសហគមន៍ក្នុងខេត្តក្រចេះ** ........ ១៥

**២.២.ការអនុវត្តសិទ្ធិគ្រប់គ្រង និងសិទ្ធិប្រើប្រាស់ដីជាសមូហភាព** ........ ១៦

២.២.១.សមាជិកសហគមន៍ ........ ១៦

២.២.២.ការកំណត់ព្រំប្រទល់ និងតំបន់ប្រើប្រាស់ដីសហគមន៍ ........ ១៧

**២.៣.ប្រភេទដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាព** ........ ១៨
**២.៤.នីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍** ........ ១៩
២.៤.១.លក្ខខណ្ឌនៃការចុះបញ្ជី........ ១៩
២.៤.២.ដំណើរការនៃការចុះបញ្ជី........ ១៩

## ជំពូកទី៣
## បញ្ហាប្រឈមនៃការបាត់បង់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច

**៣.១.កត្តាសហគមន៍** ........ ២៥
៣.១.១.កង្វះខាតការយល់ដឹងអំពីសិទ្ធិក្នុងការប្រើប្រាស់ដីសមូហភាព ........ ២៥
៣.១.២.កង្វះខាតចំណេះដឹងក្នុងការយកដីទៅចុះបញ្ជី........ ២៥
៣.១.៣.កង្វះខាតទំនុកចិត្តលើរដ្ឋាភិបាល ........ ២៦
៣.១.៤.កង្វះខាតការឯកភាពក្នុងសហគមន៍ ........ ២៦
**៣.២.កត្តាអាជ្ញាធរមូលដ្ឋាន**........ ២៧
**សេចក្តីសន្និដ្ឋាន** ........ ២៩
**អនុសាសន៍**........ ៣០
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

ព្រះរាជាណាចក្រកម្ពុជាបានប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យ ដែលមានរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេសដែលចែងពីសិទ្ធិសេរីភាព និងករណីកិច្ចរបស់ប្រជាពលរដ្ឋឲ្យមានសិទ្ធិស្មើគ្នាលើគ្រប់វិស័យ ដោយមិនប្រកាន់ជាតិសាសន៍ ពូជអំបូរ ពណ៌សម្បុរ ភេទ សាសនា ភាសា និន្នាការនយោបាយ និងស្ថានភាពផ្សេងៗទៀត។ កត្តាទាំងអស់នេះហើយទើបធ្វើឲ្យប្រទេសកម្ពុជាមានជាតិសាសន៍ចម្រុះរស់នៅ អ្នកខ្លះទទួលបានសញ្ជាតិ ខ្លះទៀតក៏ពុំទាន់បានសញ្ជាតិ។ ម៉្យាងវិញទៀត ប្រទេសកម្ពុជាមានជនជាតិដើមភាគតិចប្រមាណ ២៤ ក្រុម ដែលរស់នៅតំបន់ផ្សេងៗពីគ្នាដែលពួកគេប្រកបមុខរបរតាមបែបប្រពៃណីពីបុរាណដូចជាចម្ការវិលជុំ ចម្ការពនេចរ បរបាញ់សត្វនេសាទជាដើម។

បច្ចុប្បន្នបញ្ហាទាក់ទងទៅនឹងជម្លោះសិទ្ធិលើដីធ្លី ជម្លោះព្រំដី ការទន្ទ្រានយកដីពីសំណាក់អ្នកមានអំណាច និងការសម្បទានដីសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុនវិនិយោគ ទាំងអស់នេះហើយជាបញ្ហាចម្បងដែលរាជរដ្ឋាភិបាលកំពុងដោះស្រាយជូនបងប្អូនជនជាតិដើមភាគតិច។ បញ្ហាទាំងអស់នេះអាចកើតមានឡើងដោយសារតែចំណេះដឹងផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងសិទ្ធលើដីធ្លីពួកគាត់ដែលជាជនជាតិដើមភាគតិចនៅមានកង្វះខាត ដែលជាហេតុនាំឲ្យមានការបាត់បង់ដីធ្លីរបស់ជនជាតិដើមភាគតិច មិនត្រឹមតែបាត់បង់ដីធ្លីប៉ុណ្ណោះទេគឺអាចឈានទៅដល់ការបាត់បង់ វប្បធម៌ប្រពៃណីទំនៀមទម្លាប់ ដែលផ្សាភ្ជាប់ទៅនឹងដី មានដូចជា ដីព្រៃអារក្ស ដីព្រៃកប់ខ្មោចជាដើម។ មូលហេតុទាំងអស់នេះហើយដែលនាំឲ្យមានការស្រាវជ្រាវលើប្រធានបទ ការយល់ដឹងគតិយុត្តលើសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា៖ ករណីខេត្តក្រចេះ មកធ្វើការស្រាវជ្រាវ។

គោលបំណងក្នុងការស្រាវជ្រាវសារណានេះ គឺដើម្បីស្វែងយល់ពីបញ្ហាផ្នែកច្បាប់ថាតើជនជាតិដើមភាគតិចនៅកម្ពុជា ជាពិសេសគឺជនជាតិភាគតិចនៅខេត្តក្រចេះ មានការយល់ដឹងកម្រិតណា ក្នុងការកាន់កាប់ដីធ្លីរបស់ពួកគាត់ដោយភាពស្របច្បាប់ និងការជៀសផុតពីការបាត់បង់ដីធ្លីរបស់ពួកគាត់។

សារណានេះធ្វើការស្រាវជ្រាវដោយផ្តោតទៅលើ លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងដីធ្លីរបស់ជនជាតិដើមភាគតិច របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល បទសម្ភាសន៍ ឯកសារដែលពាក់ព័ន្ធនានា ក៏ដូចជាឯកសាររបស់មន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះ ដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវ។

សារណានេះបានចែកចេញជា ៣ជំពូក។ ជំពូកទី១ បង្ហាញពីសញ្ញាណទូទៅរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ដែលក្នុងនោះរួមមាន ប្រវត្តិ ទីតាំងភូមិសាស្ត្រ និងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច។ ចំណែកជំពូកទី២ បង្ហាញអំពីការយល់ដឹងគតិយុត្តលើសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចនៅខេត្តក្រចេះ។ រីឯជំពូកទី៣ លើកឡើងអំពីបញ្ហាប្រឈមនៃការបាត់បង់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច។

# ជំពូកទី១
# សញ្ញាណទូទៅនៃជនជាតិដើមភាគតិចនៅកម្ពុជា

ជនជាតិដើមភាគតិចនៅកម្ពុជាមានអាត្រាកើនឡើងជាលំដាប់ ដែលមានគ្រប់ចម្រុះនៃក្រុមជនជាតិដើមភាគតិច ហើយក្រុមជនជាតិដើមភាគតិចទាំងអស់កំណត់អត្តសញ្ញាណរបស់ពួកគាត់បានគឺតាមរយៈភាសា។ [សហគមន៍ជនជាតិដើមភាគតិចជាក្រុមមនុស្សដែលរស់នៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលសមាជិកទាំងអស់បង្ហាញនូវ ការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ចប្រតិបត្តិរស់នៅតាមប្រពៃណី និងការដាំដុះលើដីដែលខ្លួនបានកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព]។[1] បច្ចុប្បន្នជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជាមានចំនួន ២៤ក្រុម ដែលរស់នៅតាមបណ្តាខេត្តចំនួន ១៥ ក្នុងនោះដែរខេត្តដែលស្ថិតនៅភូមិភាគឦសាន្តគឺមានជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ។ ជនជាតិដើមភាគតិចទាំង ២៤ក្រុមនោះមានដូចជា៖ ព្នង កួយ ទំពួនចារាយ គ្រឹង ព្រៅ ការ៉ែត ស្ទៀង ក្រោល មិល កាចក់ ព័រ ខោញ ជងស្អូយ ថ្មូន លុន រដែ ខិ រអង ស្គុង ល្មិន សំរែ និងជនជាតិដើមភាគតិចផ្សេងៗទៀត។[2] ជនជាតិដើមភាគតិចទាំងនោះ បានគ្រប់គ្រងតាមបែបប្រពៃណីលើដីប្រហែល៤លានហិកតា នៃតំបន់ព្រៃដាច់ស្រយ៉ាល និងតំបន់ព្រៃស្មោង ហើយភាពសុខសាន្តរយៈពេលវែង នៃវប្បធម៌របស់ជនជាតិដើមភាគតិច បានផ្សារភ្ជាប់យ៉ាងរឹងមាំជាមួយនឹងប្រព័ន្ធនៃការប្រើប្រាស់ដីរបស់ពួកគាត់ និងការទទួលបានការប្រើប្រាស់ធនធានព្រៃឈើ ដោយភាគច្រើនពួកគាត់ប្រកបរបរកសិកម្មវិលជុំ និង ចិញ្ចឹមសត្វ រួមផ្សំនឹងការចូលក្នុងព្រៃប្រមូលផលបោចផ្តៅ បោចវល្លិ៍ ដងជ័រ បេះក្រវ៉ាញ និង រកទឹកឃ្មុំជាដើម ហើយមុខរបរតម្បាញក៏ជាប្រភពចំណូលសំខាន់មួយទៀត សម្រាប់ពួកគាត់ផងដែរ។[3]

## ១.១.ដើមកំណើតនៃជនជាតិដើមភាគតិច

ចំពោះរឿងរ៉ាវដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិចតាំងពីសម័យបុរាណមកនោះ គឺពុំមានឯកសារណាមួយដែលកត់ត្រាច្បាស់លាស់នោះទេ។ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យ នាឆ្នាំ១៩៥៤មក ព្រះបាទនរោត្តមសីហនុ ទ្រង់បានរួសរាន់បន្តនូវការអភិវឌ្ឍសេដ្ឋកិច្ចនៅតំបន់ដែលបានផ្តួចផ្តើមគំនិតឡើងដោយពួកបារាំង ហើយនៅឆ្នាំ១៩៥៩ ខេត្តរតនគិរីត្រូវបានបង្កើតឡើងជា

[1] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០សីហា ២០០១, មាត្រា២៣។

[2] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (ភ្នំពេញ, ២០០៩), ១។

[3] https://opendevelopmentcambodia.net/km/topics/ethnic-minorities-and-indigenous-people/ (ចូលទស្សនាថ្ងៃទី ២៦ មិថុនា ២០១៩)។

ខេត្តថ្មីមួយនៃខេត្តស្ទឹងត្រែង រយៈពេលភ្លាមៗបន្ទាប់ពីនេះដែរគឺនៅឆ្នាំ ១៩៥៩ ដោយមានការបង្កើតនូវខេត្តមណ្ឌលគិរី (ដែលខេត្តនេះកាលពីមុនគឺជាតំបន់ភាគខាងកើតនៃខេត្តក្រចេះ) គឺអំឡុងនេះហើយ ដែលបានកំណត់ឲ្យមានរបត់យ៉ាងសំខាន់នៅក្នុងប្រវត្តិសាស្ត្រនៃទំនាក់ទំនងរវាងជនជាតិដើមតំបន់ខ្ពង់រាប និងជនជាតិខ្មែរដែលរស់នៅតាមតំបន់ទំនាប។[4] ក្រុមទាហានខ្មែរជាច្រើន និងគ្រួសាររបស់គេត្រូវបានរដ្ឋាភិបាលបញ្ជូនទៅកាន់ខេត្តថ្មីទាំងពីរនេះ ដើម្បីអនុវត្តនូវនយោបាយសមាហរណកម្មទូទៅមួយ ចំពោះប្រជាជនកុលសម្ព័ន្ធតំបន់ខ្ពង់រាបឲ្យបានចូលទៅក្នុងសង្គមខ្មែរ ចំពោះគោលបំណងមួយក្នុងចំណោមគោលបំណងជាច្រើននៅក្នុងគោលនយោបាយនោះ គឺដើម្បីកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជននោះ (ពោលគឺការបើកឲ្យមានសាលារៀន មន្ទីរព្យាបាលរោគ មជ្ឈមណ្ឌល ដោះដូរទំនិញពាណិជ្ជកម្ម) ក្នុងនោះផងដែរការថ្លែងរបស់រដ្ឋាភិបាលបានបង្ហាញឲ្យឃើញនូវយុទ្ធនាការដ៏ខ្លាំងខ្លាដើម្បីបង្កើត និងអះអាងអំពីភាពជាកម្មសិទ្ធិ ហើយក៏បានពិពណ៌នាពីតំបន់ដែលមានប្រជាជនចម្រុះជនជាតិកំពុងរស់នៅនោះថាជា «ទឹកដីខ្មែរ» ហើយក្រុមជនជាតិទាំងនោះត្រូវស្វាគមន៍ឲ្យចូលមកនៅក្នុង «សហគមន៍ខ្មែរ» ដើម្បីឲ្យ «បងប្អូនដែលមិនបានទទួលសិទ្ធិ» ត្រូវបានទទួលនូវការការពារជារៀងរហូត។[5]

នៅសម័យសាធារណៈរដ្ឋខ្មែរ ពីឆ្នាំ១៩៧០ ដល់១៩៧៥ ដោយតំបន់ភូមិភាគឦសាន្តបានទទួលរងការទម្លាក់គ្រាប់បែកដែលធ្វើឲ្យតំបន់នោះទទួលរងការខូចខាតធ្ងន់ធ្ងរ ដោយអ្នកភូមិរស់នៅមែកខ្វែកគ្នាជាគ្រួសារតូចៗនៅតំបន់ដាច់ស្រយាល មិនហ៊ានរស់នៅប្រមូលផ្តុំគ្នានោះទេ។[6]

ក្រោយពីសម័យសាធារណៈខ្មែរបានឆ្លងផុត សម័យកម្ពុជាប្រជាធិបតេយ្យក៏បានឈានមកដល់(ឆ្នាំ១៩៧៥ ដល់ ១៩៧៩) ជាអំឡុងពេលដែលអ្នកភូមិត្រូវបានគេបង្ខំឲ្យចាកចេញទៅទីកន្លែងផ្សេងៗ ឆ្ងាយពីស្រុកកំណើតរបស់ពួកគេ ដោយតំបន់មួយមានភូមិជាច្រើនរួមបញ្ចូលគ្នាដោយឲ្យរស់នៅជាលក្ខណៈប្រមូលផ្តុំ រស់នៅក្នុងផ្ទះរួមគ្នា ធ្វើស្រែរួមគ្នា និងត្រូវហាមប្រាមមិនឲ្យស្លៀកសម្លៀកបំពាក់បែបប្រពៃណីជនជាតិដើមនោះទេដូចជា ប៉ឹង សំពត់ត្បាញដោយដៃ និងគ្រឿង

[4]មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៤៧៤។

[5]មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៤៧៥។

[6]មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៤៧៦, ៤៧៧ ។

អលង្ការតុបតែងជាដើម។[7] ម៉្យាងវិញទៀតពិធីសែនព្រេនតាមបែបប្រពៃណីដូចជា ការសម្លាប់សត្វដើម្បីបូជាដល់ព្រលឹង និងពិធីសែនព្រេនផ្សេងៗដែលទាក់ទងទៅនឹងព្រលឹងនោះ ត្រូវចាត់ទុកថាខុសច្បាប់ ដោយសារឋានៈពួកគេជាជនជាតិដើមភាគតិច ហើយមានប្រវត្តិសាស្ត្រសាវតាខុសគ្នាផង គឺសម័យកម្ពុជាប្រជាធិបតេយ្យបាននាំឲ្យមានការផ្លាស់ប្តូរ និងចាប់អារម្មណ៍មួយចំនួន ដែលជនជាតិខ្មែរមិនដែលជួបប្រទះដូចពួកគេ តែក៏ជាអំឡុងពេលមួយដ៏ល្អដែលទំនាក់ទំនងរបស់ពួកគេជាមួយប្រជាជនខ្មែរមានភាពប្រសើរឡើង ដោយពួកគេបានរស់នៅ និងទទួលរងការឈឺចាប់ជាមួយគ្នា និងជាអំឡុងពេលដែលពួកអ្នកភូមិមួយចំនួនរៀនភាសាខ្មែរជាលើកដំបូង ដែលពួកគេគិតថាមានសារៈសំខាន់សម្រាប់ពួកគេ។[8]

បន្ទាប់ពីបានឆ្លងផុតនូវការរងឈឺចាប់ និងទុក្ខវេទនា បែកបាក់គ្រួសារពីសម័យកម្ពុជាប្រជាធិបតេយ្យមក ស្ទើរតែគ្រប់ជនជាតិដើមតំបន់ខ្ពង់រាបទាំងអស់បានវិលត្រឡប់ទៅកាន់ភូមិកំណើតរបស់ពួកគេវិញ ដោយភូមិជាច្រើនត្រូវបានសាងសង់ឡើងវិញនៅលើទីតាំងដើម តែអ្នកភូមិមួយចំនួនក៏បានសង់នៅលើទីតាំងថ្មីក្បែរនឹងទីតាំងចាស់ព្រោះដីចាស់នោះ «ក្តៅ» មានសកម្មភាពនៃព្រលឹង គ្រប់ភូមិទាំងអស់បានយកឈ្មោះភូមិចាស់ប្រើ ហើយព្រឹទ្ធាចារ្យប្រចាំភូមិដែលនៅរស់រានជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យ បានទទួលបន្ទុកសែនព្រេនទៅតាមសាសនាចំពោះព្រលឹងដើម្បីបង្កើតឡើងវិញនូវទំនាក់ទំនងរវាងព្រលឹងដែលជួយការពារ ដែលត្រូវបានគេកាត់ផ្តាច់ ទើបនាំឲ្យមានការបង្កើតឡើងវិញនូវអត្តសញ្ញាណក្រុមរបស់ពួកគេ។[9] ហេតុដូចនេះហើយ ទំនៀមទម្លាប់ទាំងនោះ គឺជាមូលដ្ឋានដ៏សំខាន់នៃជីវិតរស់នៅរបស់ជនជាតិដើមតំបន់ខ្ពង់រាប ហើយកត្តានេះហើយបានផ្តល់នូវអត្តសញ្ញាណ និងជីវភាពសហគមន៍នាពេលបច្ចុប្បន្ននេះ។

### ១.១.១.អត្តសញ្ញាណ

គ្រប់ជនជាតិដើមភាគតិចទាំងអស់មិនថារស់នៅទីណា ឬតំបន់ណានោះទេគឺមានអត្តសញ្ញាណសម្គាល់របស់ក្រុមរៀងៗខ្លួន ដោយអត្តសញ្ញាណនោះដែរក៏មានទំនាក់ទំនងជាមួយទី

[7]មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៤៧៨។

[8]មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៤៧៩។

[9]មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៤៨០, ៤៨១។

តាំង ឬតំបន់ដែលពួកគេរស់នៅ ឬក៏អាចជាដីធ្លីដែលពួកគេប្រើប្រាស់ដើម្បីរស់នៅផងដែរ។ ការអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជាអំពីអត្តសញ្ញាណរបស់បុគ្គល ឬវត្ថុអ្វីមួយដោយផ្អែកទៅលើ៖ [ឈ្មោះ ភេទ អាយុ អាសយដ្ឋាន សញ្ជាតិ ដើមកំណើតជាតិសាសន៍ ភិនភាគស្លាកស្នាម -ល- ដើម្បីស្គាល់ថាជាក្រុមជនជាតិដើមភាគតិចអ្វីមួយ ឬបុគ្គលណាមួយមានសញ្ញាណអ្វី ឬជាវត្ថុអ្វីមួយ]។[10]

ការកំណត់អត្តសញ្ញាណតាមរយៈ ភេទ អាយុ និងឈ្មោះ សហគមន៍ជនជាតិដើមភាគតិចសំដៅទៅលើក្រុមមនុស្ស ឬជានីតិបុគ្គល [ប្រសិនបើមិនបានចុះបញ្ជីជាមួយរដ្ឋត្រឹមត្រូវនោះទេ គឺមិនអាចសម្គាល់បានតាមរយៈភេទ ឬអាយុបានទេ តែបើសិនមានការចុះបញ្ជីជាមួយរដ្ឋ គឺអាចវាស់វែង ឬកត់សម្គាល់បានតាមរយៈការចុះបញ្ជីនោះ ក៏ប៉ុន្តែមិនមែនមានន័យថាសម្គាល់អាយុកាលរបស់សហគមន៍ជនជាតិដើមភាគតិចទៅតាមច្បាប់នៃធម្មជាតិនោះទេ] ដោយពុំមានឯកសារណាមួយបញ្ជាក់ច្បាស់ថាសហគមន៍ជនជាតិដើមភាគតិចដែលនៅក្នុងព្រះរាជាណាចក្រមានអាយុកាលតាំងពីពេលណានោះទេ ហេតុដូចនេះហើយអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចមិនអាចបាត់បង់បានដោយសារតែមិនដឹងពីភេទ និងអាយុកាលឡើយ។[11] ក្រុមជនជាតិខ្លះមានខ្សែស្រលាយ ឬអម្បូរ ដូចជា ជនជាតិដើម ចារាយ ទំពួន ការចក់ មានត្រកូលសម្គាល់បានដូចជា៖ រម៉ាស់ រចំ សេវ ក្លោង ទីង សល់ រប៉ូច ក្លាន ក្លាហ្ស សន្លង់ ជាដើម។[12]

ការកំណត់អត្តសញ្ញាណតាមរយៈ អាសយដ្ឋាន សញ្ជាតិ និងដើមកំណើតជាតិសាសន៍ អត្តសញ្ញាណដែលកំណត់ដោយអាសយដ្ឋាន គឺ [កំណត់តាមរយៈទីតាំងភូមិសាស្ត្រ និងតំបន់ដែលពួកគេរស់នៅដូចជា តំបន់ខ្ពង់រាប និងតំបន់ភ្នំជាដើម ចំពោះដើមកំណើតរបស់ជនជាតិនីមួយៗមិនអាចកែប្រែ ឬផ្លាស់ប្តូរបាននោះទេ ប៉ុន្តែសញ្ញាណ ឬសញ្ជាតិ អាចកែប្រែទៅតាមច្បាប់ និងនិន្នាការនយោបាយរបស់ប្រទេស] ។[13]

ការកំណត់អត្តសញ្ញាណតាមរយៈភិនភាគស្លាកស្នាម ដោយភិនភាគស្លាកស្នាមរបស់សហគមន៍អាចកំណត់អត្តសញ្ញាណរបស់សហគមន៍បាន និងអាចកំណត់សម្គាល់តាមរយៈ [ឈ្មោះក្រុមជនជាតិ ភាសា ដែនដី ជំនឿ ប្រពៃណី វប្បធម៌ អរិយធម៌ -ល- ហើយការសម្គាល់អត្តសញ្ញាណរបស់ជនជាតិដើមភាគតិចតាមរយៈជំនឿនោះ គឺជំនឿទៅលើ ព្រៃអារក្ស អ្នកតា] ។[14]

---

[10] ហេង ឆ្លូញ "ជនជាតិដើមភាគតិចជាមួយនឹងសិទ្ធិលើអចលនៈវត្ថុ" (ថតចម្លងថ្ងៃទី ០៦ កក្កដា ២០១៥)។

[11] ហេង ឆ្លូញ "ជនជាតិដើមភាគតិចជាមួយនឹងសិទ្ធិលើអចលនៈវត្ថុ" (ថតចម្លងថ្ងៃទី ០៦ កក្កដា ២០១៥)។

[12] ហេង ឆ្លូញ "ជនជាតិដើមភាគតិចជាមួយនឹងសិទ្ធិលើអចលនៈវត្ថុ" (ថតចម្លងថ្ងៃទី ០៦ កក្កដា ២០១៥)។

[13] ហេង ឆ្លូញ "ជនជាតិដើមភាគតិចជាមួយនឹងសិទ្ធិលើអចលនៈវត្ថុ" (ថតចម្លងថ្ងៃទី ០៦ កក្កដា ២០១៥)។

[14] ហេង ឆ្លូញ "ជនជាតិដើមភាគតិចជាមួយនឹងសិទ្ធិលើអចលនៈវត្ថុ" (ថតចម្លងថ្ងៃទី ០៦ កក្កដា ២០១៥)។

### ១.១.២. ស្ថានភាពជីវភាពរស់នៅ

ចំពោះស្ថានភាពរស់នៅនាសម័យដើមនោះគឺពុំមានការកត់ត្រាគ្រប់គ្រាន់សម្រាប់ស្រាវជ្រាវនោះទេ តែដឹងត្រឹមថាការរស់នៅរបស់ជនជាតិដើមភាគតតិច [កាលពីមុន គឺរស់នៅតាមបែបប្រពៃណីបុរាណ ទាំងការរស់នៅ ទាំងការហូបចុក ការសែនព្រេន ការរកស៊ី គឺអាស្រ័យទៅលើអនុផលព្រៃឈើ ការបរបាញ់សត្វព្រៃ និងធ្វើស្រែចម្ការដើម្បីផ្គត់ផ្គង់ជីវភាព ចំណែកនាពេលគ្រុនក្តៅ គឺមានជំនឿទៅលើការសែនព្រេន អារុកអារក្ស អ្នកតា] ។[15] ចំពោះការប្រកបរបរកសិកម្ម ការដាំដុះធ្វើស្រែចម្ការគឺពួកគេធ្វើទៅតាមទម្លាប់ ប្រពៃណីពីដូនតាដោយមិនមានការស្វែងយល់ពីជំនាញកសិកម្មត្រឹមត្រូវ តែបច្ចុប្បន្នដោយមានការដឹកនាំដ៏ត្រឹមត្រូវពីសំណាក់ប្រមុខរាជរដ្ឋាភិបាលដោយមានគោលនយោបាយលើកកម្ពស់ជីវភាពរបស់បងប្អូនជនជាតិដើមភាគតិចតាមការអភិវឌ្ឍផ្នែកផលិតកម្មកសិកម្ម ក៏ឃើញមានការប្រែប្រួលគួរឲ្យកត់សម្គាល់ទាំងការរស់នៅ និងការប្រកបរបរកសិកម្មមានការយល់ដឹងពីរបៀបកសិកម្មច្រើនជាងកាលពីសម័យមុនពួកគេ ដោយមានការចុះណែនាំពីមន្ត្រីរាជការ ដូចជា មន្ត្រីសង្គមស៊ីវិលដែលបានចុះធ្វើការផ្សព្វផ្សាយ អប់រំ តាមមូលដ្ឋានឬសហគមន៍របស់ពួកគេ។[16] ហើយចេះនាំយកផលិតផលយកទៅលក់នៅទីផ្សារ ដើម្បីបានប្រាក់បន្ថែមសម្រាប់ធ្វើឲ្យជីវភាពរបស់ពួកគេមានភាពធូរជារប្រសើរជាងមុន និងពេលមានជំងឺឈឺថ្កាត់ភាគច្រើនពួកគេនាំគ្នាងាកទៅរកសេវាព្យាបាលនៅមន្ទីរពេទ្យ តែទោះជាយ៉ាងណាក៏ដោយក៏ជនជាតិដើមភាគតិចមិនកែប្រែ ឬលុបបំបាត់ទំនៀមទម្លាប់ជំនឿរបស់ពួកគេទាំងស្រុងដែរ។

### ១.១.៣.វប្បធម៌ ប្រពៃណី និងការអប់រំ

វប្បធម៌ មានន័យថា [ជាបណ្តុំនៃចំណេះដឹង មានដូចជា ជំនឿ សាសនា តាមរយៈ ភាសា អក្សរ អក្សរសាស្ត្រ អក្សរសីល្ប៍ សិល្បៈ ដែលអនុវត្តជាទម្លាប់ ទំនៀមទម្លាប់ប្រពៃណី ការអប់រំ និងល្បែងកំសាន្តជាដើម -ល-] ។[17] គ្រប់ក្រុមជនជាតិដើមភាគតិចទាំងអស់ គឺមានវប្បធម៌ ប្រពៃណីសម្រាប់ក្រុមរៀងៗខ្លួន ដែលមានតាមរយៈការគោរពចាស់ទុំ ចាស់ព្រឹទ្ធាចារ្យ អ្នកតា ព្រៃអារក្ស ព្រៃកប់ខ្មោច ការសែនព្រេន ភាសា និងសម្លៀកបំពាក់ជាដើម។[18] បើក្រឡេកមើលនាពេលបច្ចុប្បន្នវិញ

---

[15] មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៤៦៤,៤៦៥។

[16] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (ភ្នំពេញ, ២០០៩), ១០,១១។

[17] ត្រឹង ងា, *អរិយធម៌ខ្មែរ* (១៩៧៤), ១៣។

[18] មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៤៨៤,៤៨៥។

ដោយសង្គមមានការរីកចម្រើនជឿនលឿន អាចធ្វើឲ្យប្រពៃណីជនជាតិដើមភាគតិចមួយចំនួនមានការបាត់បង់បណ្តើរៗទៅតាមរបត់នៃសង្គម ដូចជាការស្លៀកពាក់ នៅមានចាស់ៗមួយចំនួនដែលនៅស្លៀកពាក់ សម្លៀកបំពាក់ប្រពៃណី តែចំពោះយុវជនវិញគឺមានការស្លៀកពាក់ដូចបងប្អូនខ្មែរទូទៅដែរ តែទោះជាយ៉ាងណាក៏ពួកគេមិនលុបបំបាត់វប្បធម៌ប្រពៃណីរបស់ពួកទាំងស្រុងដែរ ដូចជា ជំនឿសែនព្រេន ការបន់ស្រន់ គោរពព្រៃអារក្ស នៅតែមានដល់បច្ចុប្បន្ន។

ចំពោះការអប់រំកូនចៅរបស់ជនជាតិដើមភាគតិចវិញ កាលពីជំនាន់មុនគឺការអប់រំធ្វើឡើងតាមរយៈផ្ទេរចំណេះដឹងពីឪពុកម្តាយតទៅកូនចៅពីមួយជំនាន់ទៅមួយជំនាន់ ហើយក្មេងៗជំនាន់នោះភាគច្រើនមិនបានទៅសិក្សានៅឯសាលារៀននោះទេ ណាមួយពួកគេរស់នៅតំបន់ដាច់ស្រយាលឆ្ងាយពីសាលារៀន និងមិនទាន់មានសាលារៀនគ្រប់គ្រាន់ ហើយមួយចំនួនទៀតពួកគេរវល់ជួយការងារឪពុកម្តាយដូចជាការធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត ដែលជាហេតុពួកគេមិនមានចំណេះដឹងជ្រៅជ្រះ។[19]

តែបច្ចុប្បន្នរាជរដ្ឋាភិបាលក៏បានជួយជ្រុមជ្រែងរក្សាការពារនូវវប្បធម៌របស់ជនជាតិដើមភាគតិច ដោយបង្កើតសារមន្ទីរ និងមជ្ឈមណ្ឌលវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច ដោយមានការពិគ្រោះយោបល់ និងឯកភាពពីជនជាតិដើមភាគតិច ដើម្បីសិក្សា និងការពារវប្បធម៌ ដូចជាទំនៀមទម្លាប់ប្រពៃណីល្អ ភាសា ចំណេះដឹង ទស្សនៈ តម្លៃ ជំនឿ និងសិល្បៈផ្សេងៗទៀត។[20] ចំពោះវិស័យអប់រំវិញរាជរដ្ឋាភិបាលបានសាងសង់សាលារៀនបន្ថែម និងរៀបចំប្រព័ន្ធអប់រំពេញលេញសមស្របទៅតាមតម្រូវការរបស់បងប្អូនជនជាតិដើមភាគតិចដោយពង្រាយគ្រូឲ្យទៅបង្រៀននៅកន្លែងខ្វះគ្រូឬគ្មានគ្រូ ដើម្បីឲ្យពួកគាត់បន្តការសិក្សានៅសាលាមធ្យមសិក្សា សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងឧត្តមសិក្សា។[21]

## ១.២.ទីតាំងភូមិសាស្ត្ររបស់ជនជាតិដើមភាគតិចនៅកម្ពុជា

នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានជនជាតិដើមភាគតិចរស់នៅ២៤ក្រុម ក្នុងខេត្តចំនួន១៥នៃចំនួនខេត្តទាំង២៤ តែបើក្រឡេកមើលខេត្តទាំង១៥ដែលជនជាតិដើមភាគតិចកំពុងរស់នៅនោះគឺមានតែខេត្តដែលស្ថិតនៅភូមិភាគឦសាន្តទេដែលមានជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ។

[19] មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៦០០។

[20] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (ភ្នំពេញ, ២០០៩), ៥។

[21] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (ភ្នំពេញ, ២០០៩), ៦។

ដោយខេត្តទាំង១៥ នោះមានក្រុមជនជាតិដើមភាគតិចរស់នៅមានដូចជា៖ ខេត្តក្រចេះ មានក្រុមជនជាតិដើមភាគតិច ព្នង កួយ ស្ទៀង មិល ក្រោល ថ្មូន ខោញ[22] , ខេត្តរតនៈគិរី មានក្រុមជនជាតិដើមភាគតិច គ្រឹង ចារាយ ទំពួន ព្រៅ ពូនង កាវ៉ែត កាចក់ លុន រដែ , ខេត្តមណ្ឌលគិរី មានក្រុមជនជាតិដើមភាគតិច ពូនង គ្រឹង ចារាយ ក្រោល ស្ទៀង ថ្មូន កួយ ទំពួន , ខេត្តស្ទឹងត្រែង មានក្រុមជនជាតិដើមភាគតិច ពូនង គ្រឹង ចារាយ កួយ ទំពួន , ខេត្តព្រះវិហារ បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តកំពង់ធំ មានក្រុមជនជាតិដើមភាគតិច កួយ , ខេត្តកំពង់ស្ពឺ មានក្រុមជនជាតិដើមភាគតិច សួយ , ខេត្តពោធិសាត់ មានក្រុមជនជាតិដើមភាគតិច ព័រ ជង , ខេត្តកំពង់ចាម មានក្រុមជនជាតិដើមភាគតិច ស្ទៀង , ខេត្តកោះកុង មានក្រុមជនជាតិដើមភាគតិច ជង , ខេត្តព្រះសីហនុ មានក្រុមជនជាតិដើមភាគតិច ស្អូច , ខេត្តបាត់ដំបង មានក្រុមជនជាតិដើមភាគតិច ព័រ , ខេត្តសៀមរាប មានក្រុមជនជាតិដើមភាគតិច ព្នង។[23]

## ១.៣.បទដ្ឋានគតិយុត្តជាតិដែលអនុវត្តចំពោះជនជាតិដើមភាគតិច

### ១.៣.១.រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា [ជនគ្រប់រូបមាន សិទ្ធិរស់រានមានជីវិត មានសេរីភាពនិងមានសន្តិសុខផ្ទាល់ខ្លួន ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ] ។[24] ម៉្យាងវិញទៀត បើក្រឡេកមើលអំពីសហគមន៍ជនជាតិដើមភាគតិចវិញ ពួកគាត់ក៏ជាពលរដ្ឋកម្ពុជា។ យ៉ាងណាមិញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ សិទ្ធិលើកម្មសិទ្ធិសម្ហូភាពរបស់នីតិបុគ្គល ឬបុគ្គលទាំងឡាយណាដែលមានសញ្ជាតិខ្មែរ។[25] ដូច្នេះហើយនៅពេលដែលសហគមន៍ជនជាតិដើមភាគតិចទទួលបានសញ្ជាតិខ្មែររួចហើយ ពួកគាត់នឹងមានសិទ្ធិពេញលេញលើអចលនវត្ថុដែលគាត់ប្រើប្រាស់ គឺដីសម្ហូភាព ។

### ១.៣.២.ច្បាប់ភូមិបាល

ច្បាប់ភូមិបាលឆ្នាំ១៩៩២ ពុំមានចែងអំពើសិទ្ធិដីសម្ហូភាពណាមួយឡើយ ។ ទន្ទឹមនឹងនេះចំពោះដីសម្ហូភាពរបស់ជនជាតិដើមភាគតិចនៅមិនទាន់ទទួលស្គាល់ ឬផ្តល់សិទ្ធិដោយច្បាប់ភូមិបាលឆ្នាំ១៩៩២ទេ ។ បន្ថែមជាងនេះទៅទៀត ក្រោយពីបានអនុវត្តច្បាប់ភូមិបាលឆ្នាំ១៩៩២

[22] ឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ (ក្រចេះ៖ មន្ទីរផែនការខេត្ត, មីនា ២០១៩)។

[23] មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់, *ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា* (គ្រឹះស្ថានបោះពុម្ពសាស្ត្រា), ៥៨២។

[24] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៣២។

[25] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៤៤។

ហើយ រដ្ឋាភិបាលបានមើលឃើញអំពីភាពខ្វះចន្លោះដែលបង្កការលំបាកអ្នកអនុវត្ត ទើបរាជរដ្ឋាភិបាលសម្រេចកោះប្រជុំជាមួយគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាក់ព័ន្ធបង្កើតច្បាប់ភូមិបាលថ្មីគឺច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ។ ច្បាប់ភូមិបាល ឆ្នាំ ២០០១ [ទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចណាមួយបង្ហាញនូវការឯកភាពនៃជាតិពន្ធុ (មានន័យថាសំដៅដល់អត្តសញ្ញាណរបស់ក្រុមមនុស្សដែលមានទំនាក់ទំនងនឹងគ្នាដោយមានការបូកបញ្ចូលគ្នានៃវប្បធម៌ សាសនា ប្រវត្តិសាស្រ្ត និងទីតាំងភូមិសាស្រ្តដោយឡែក) សង្គមវប្បធម៌ និងសេដ្ឋកិច្ច រស់នៅតាមបែបប្រពៃណី និងការដាំដុះលើដីដែលពួកគាត់បានកាន់កាប់តាមទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព]។[26]

បន្ថែមជាងនេះទៅទៀត ដើម្បីឲ្យបង្ហាញយ៉ាងច្បាស់ថាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិចដែលច្បាប់ភូមិបាលបានការពារ គឺរាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិពន្ធុ វប្បធម៌ និងសង្គមរបស់សហគមន៍ ដែលពួកគាត់ទទួលស្គាល់មតិភាគច្រើន និងយល់ព្រមទទួលនូវសាមគ្គីភាពចំណុះដែលនាំឲ្យមានកំលាំងចូលរួមក្នុងសហគមន៍។[27] នៅក្នុងប្រទេសកម្ពុជាច្បាប់ភូមិបាលបានបង្ហាញយ៉ាងច្បាស់ថា "កម្មសិទ្ធិសមូហភាពរួមមានរាល់ទាំងសិទ្ធិនិងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជន" ។[28] ទោះបីយ៉ាងណា សហគមន៍គ្មានចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាពដែលជាទ្រព្យសម្បត្តិរបស់សាធារណៈរបស់រដ្ឋទៅឲ្យបុគ្គលណាមួយ ឬក្រុមណាមួយឡើយ។[29] ទន្ទឹមនឹងនេះសមាជិកសមាគមន៍ជនជាតិដើមភាគតិចអាចទទួលគុណប្រយោជន៍និងការធានារក្សាសិទ្ធិដោយច្បាប់។[30] ការទទួលជាផ្លូវការនៃសិទ្ធិដីធ្លីតាមលក្ខណៈប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាលផងដែរ ។[31]

### ១.៣.៣.ច្បាប់ព្រៃឈើ

ច្បាប់ព្រៃឈើឆ្នាំ ២០០២ ជាច្បាប់សម្រាប់ការគ្រប់គ្រងដីមិនថាដីព្រៃសម្បទាន ព្រៃការពារ ដីព្រៃសហគមន៍ ដីឯកជន ក្នុងនោះផងដែរសហគមន៍ជនជាតិដើមភាគតិចដែលជាដីប្រពៃណីសម្រាប់ប្រកបរបរចម្ការពនេចរ ដែលបានចុះបញ្ជីកាជាមួយរដ្ឋរួច ហើយអាចអនុវត្តលើកម្មសិទ្ធិដី

[26] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៤៥។
[27] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០សីហា ២០០១, មាត្រា២៤។
[28] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០សីហា ២០០១, មាត្រា២៦។
[29] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២៦។
[30] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២៤។
[31] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២៥។

បាន។[32] ម្យ៉ាងវិញទៀត សហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិប្រើប្រាស់ដីប្រពៃណី ប៉ុន្តែរដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់សម្រាប់គោលបំណងទំនៀមទម្លាប់ ជំនឿ សាសនា និងការរស់នៅ។[33] ព្រៃសហគមន៍ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសេដ្ឋកិច្ច និងដោយធានានិរន្តភាពដោយសហគមន៍មូលដ្ឋាន តាមផែនការរបស់ការគ្រប់គ្រងសហគមន៍ វិធានសហគមន៍ព្រៃឈើ និងគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។[34] វិធានការសម្រាប់បង្កើត ការគ្រប់គ្រង និងការប្រើប្រាស់ព្រៃសហគមន៍ ត្រូវបានកំណត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ។[35]

### **១.៣.៤.ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ**

តំបន់ការពារធម្មជាតិនីមួយៗ ត្រូវបែងចែកជា៤តំបន់គ្រប់គ្រងដែលក្នុងនោះមានមួយជា ″តំបន់សហគមន៍″ ដែលមានការគោរពដល់ការកាន់កាប់ដីធ្លីតាមលក្ខណៈប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច។[36] ការទទួលស្គាល់បែបនេះមានលក្ខណៈល្អប្រសើរបំផុត ហើយការកំណត់តំបន់គ្រប់គ្រងឲ្យបានពេញលេញនៅក្នុងតំបន់ការពារធម្មជាតិទាំងអស់គឺជាជំហានដ៏ល្អប្រសើរសម្រាប់ការទទួលស្គាល់និងសុវត្ថិភាពនៃការកាន់កាប់ដីធ្លីតាមលក្ខណៈប្រពៃណីរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ការទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លីដែលបានកើតឡើងនេះហាក់ដូចជាមិនទាន់ទូទំទូលាយនៅឡើយ ពិសេសសម្រាប់សហគមន៍ជនជាតិដើមភាគតិចព្រោះវារួមបញ្ចូលតែដីលំនៅដ្ឋាន ដីស្រែ ដីចម្ការ ឬដីសម្រាប់ចម្ការវិលជុំតែប៉ុណ្ណោះ ប៉ុន្តែមិនបានរាប់បញ្ចូលប្រភេទដីផ្សេងទៀតដូចជាដីព្រៃអារក្ស និងដីព្រៃកប់ខ្មោចជាដើម។ សិទ្ធិប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណីទំនៀមទម្លាប់ តាមតម្រូវការរបស់សហគមន៍ជនជាតិដើមភាគតិចលក្ខណៈគ្រួសារនៅក្នុងតំបន់ចីរភាព និងតំបន់អភិរក្ស។[37] ការប្រើប្រាស់ធនធានធម្មជាតិ ត្រូវអនុវត្តតាមផែនការគ្រប់គ្រងនិងបែបបទបច្ចេកទេស ដើម្បីធានានិរន្តភាពនៃធនធានធម្មជាតិនៅក្នុងសហគមន៍។[38] ចំពោះការអនុវត្តមុខរបរចម្ការពនេចរ ត្រូវហាមឃាត់ក្នុងតំបន់ស្នូល និងតំបន់អភិរក្សក្នុងតំបន់ការពារធម្មជាតិ។[39] កិច្ចព្រមព្រៀងមួយដែលមានសុពលភាពមិនលើសពីរយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំម្តងត្រូវធ្វើឡើងរវាង

---

[32] ច្បាប់ព្រៃឈើ, លេខ នស/រកម/០៨០២/០១៦, ៣១ សីហា ២០០២, មាត្រា៣៧។

[33] ច្បាប់ព្រៃឈើ, លេខ នស/រកម/០៨០២/០១៦, ៣១ សីហា ២០០២, មាត្រា៤០។

[34] ច្បាប់ព្រៃឈើ, លេខ នស/រកម/០៨០២/០១៦, ៣១ សីហា ២០០២, មាត្រា៤៣(១)។

[35] ច្បាប់ព្រៃឈើ, លេខ នស/រកម/០៨០២/០១៦, ៣១ សីហា ២០០២, មាត្រា៤៣(៤)។

[36] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, លេខ នស/រក/០២០៨/០០៧, ១៥ កុម្ភៈ ២០០៨, មាត្រា១១។

[37] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, លេខ នស/រក/០២០៨/០០៧, ១៥ កុម្ភៈ ២០០៨, មាត្រា២២(១)។

[38] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, លេខ នស/រក/០២០៨/០០៧, ១៥ កុម្ភៈ ២០០៨, មាត្រា២៣(២)។

[39] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, លេខ នស/រក/០២០៨/០០៧, ១៥ កុម្ភៈ ២០០៨, មាត្រា២៤។

សហគមន៍តំបន់ការពារធម្មជាតិ ជាមួយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។[40] ករណីដែលសហគមន៍តំបន់ការពារធម្មជាតិមិនអនុវត្តចំពោះកិច្ចព្រមពៀង នោះរដ្ឋបាលការពារ និងអភិរក្សធម្មជាតិមានសិទ្ធិផ្អាកដំណើរការនៅក្នុងតំបន់ ដើម្បីធ្វើការពិនិត្យ និងវាយតម្លៃឡើងវិញ ។[41] ក្រសួងបរិស្ថានមានសិទ្ធិលុបកិច្ចព្រមព្រៀងក្នុងករណីសហគមន៍អនុវត្តផ្ទុយពីកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រង។[42] ជនជាតិដើមភាគតិច ពុំមានសិទ្ធិកាប់គាស់ ឬឈូសឆាយដីព្រៃ សម្រាប់ធ្វើកម្មសិទ្ធិបុគ្គល ឬលក់ ដូរ បញ្ចាំ ឲ្យទៅរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយឡើយ។[43]

## ១.៣.៥.គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច

ក្រោយពីការបោះឆ្នោតជាទូទៅនៅក្នុងឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវអន្តរក្រសួងសម្រាប់ការធ្វើការជាមួយការអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ក្នុងគម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ដែលមានក្រសួងអភិវឌ្ឍន៍ជាប្រធាន និង ជាអ្នកភ្នាក់ងារអនុវត្ត និងក្រោយមកទៀតក៏បានបង្កើតនូវ "នាយកដ្ឋានអភិវឌ្ឍន៍ជាជនជាតិដើមភាគតិច" ចំណុះឲ្យក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងគោលបំណង ដើម្បីលើកស្ទួយកម្រិតជីវភាពរស់នៅរបស់បងប្អូនជនជាតិដើម ព្រមទាំងថែរក្សាវប្បធម៌ ប្រពៃណី ទំនៀមទំលាប់ ប្រពៃណី និងជំនឿរបស់ពួកគេ។[44] ដោយមានការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ជនជាតិដើមភាគតិចទាំងអស់ ត្រូវមានជីវភាពរួចផុតពីការស្រេចឃ្លាន និងភាពក្រីក្រធ្ងន់ធ្ងរ [ហើយ] ជនជាតិដើមភាគទាំងអស់ត្រូវតែបានផ្តល់ការអប់រំយ៉ាងតិចមូលដ្ឋាន ៩ឆ្នាំ និងត្រូវផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សមស្របទៅតាមតំរូវការ និងផ្អែកតាមលើទីតាំងភូមិសាស្ត្ររបស់បងប្អូន [ចំពោះ] សុខភាពរបស់ជនជាតិដើមភាគតិចត្រូវថែរក្សាឲ្យបានល្អប្រសើរ [និង] វប្បធម៌របស់ជនជាតិដើមភាគតិចត្រូវការពារ និងថែរក្សាឲ្យបានល្អប្រសើរ ។[45]

---

[40] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, លេខ នស/រក/០២០៨/០០៧, ១៥ កុម្ភៈ ២០០៨, មាត្រា២៥(២)។
[41] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, លេខ នស/រក/០២០៨/០០៧, ១៥ កុម្ភៈ២០០៨, មាត្រា២៥(៣)។
[42] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, លេខ នស/រក/០២០៨/០០៧, ១៥ កុម្ភៈ២០០៨, មាត្រា២៥(៤)។
[43] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, លេខ នស/រក/០២០៨/០០៧, ១៥ កុម្ភៈ២០០៨, មាត្រា២៦។
[44] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច, ២៤ មេសា ២០០៩, ២។
[45] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច, ២៤ មេសា ២០០៩, ២។

### ១.៣.៦.គោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច

ដី គឺជាលក្ខខណ្ឌមួយនៃសន្តិសុខបុគ្គល និងការរួបរួមនៅក្នុងក្រុម ។[46] ការទទួលបានដី ការទទួលស្គាល់ ការកំណត់ព្រំដី និងការចុះបញ្ជីដី តំណាងឲ្យសិទ្ធិដ៏សំខាន់ សម្រាប់ការរស់រានខាងវប្បធម៌ និងសម្រាប់រក្សាសេចក្តីថ្លៃថ្នូររបស់សហគមន៍ ដើម្បីធានាសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ចំពោះអចលនទ្រព្យសហគមន៍ ចាំបាច់ត្រូវចាត់ទុកថា ដីគឺផ្សារភ្ជាប់យ៉ាងជិតស្និទ្ធ ទៅនឹងប្រពៃណី ទំនៀមទម្លាប់ និងភាសាសិល្បៈ និងការបន់ស្រន់ ពុទ្ធិនិងទម្លាប់អនុវត្តរបស់ពួកគេទាក់ទងនឹងធម្មជាតិ សិល្បៈធ្វើម្ហូប ច្បាប់ប្រពៃណី សម្លៀកបំពាក់ ទស្សនៈវិជ្ជា និងគុណតម្លៃ ។[47] សព្វថ្ងៃ ប្រព័ន្ធកសិកម្មជឿនលឿនត្រូវតែមានការគិតគូរឲ្យបានសមស្រប ដើម្បីកែលម្អកសិកម្មតាមបែបប្រពៃណីទៅជាកសិកម្មប្រពលវប្បកម្ម ការដាំដុះដំណាំដែលផ្តល់ផលខ្ពស់ដោយមិនចាំបាច់ធ្វើ បំលាស់ទីច្រើនកន្លែងដូចពីមុន ហើយដើម្បីទទួលបានគុណភាពខ្ពស់ និងមានទីផ្សារ ។

គោលបំណង និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការចុះបញ្ជីដីធ្លីជូនសហគន៍ជនជាតិជនជាតិដើមភាគតិចជាចំណែកមួយនៃដំណើរការគ្រប់គ្រងដីធ្លីនៅកម្ពុជា ធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងរួមចំណែកដល់ :

១.ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយបង្កលក្ខណៈឲ្យសហគមន៍ជនជាតិដើមភាគមាន ដីធ្លី និងមានសិទ្ធិប្រើប្រាស់ធនធានធម្មជាតិផ្សេងទៀត សម្រាប់ទ្រទ្រង់ជីវភាពរស់នៅ សន្តិសុខស្បៀង និង ការអភិវឌ្ឍសហគមន៍របស់ខ្លួន ។

២.ការគ្រប់គ្រងដីធ្លីប្រកបដោយនិរន្តភាព តាមរយៈការកសាងផែនការប្រើប្រាស់ និង ការគ្រប់គ្រងដីធ្លី ដោយធ្វើប្រព័ន្ធកសិកម្មប្រពៃណីរបស់ជនជាតិដើមភាគតិចអាចបន្សាំទៅនឹងការវិវត្តន៍ប្រែប្រួលរបស់សង្គមជាតិ ។

៣.ការបំបាត់សកម្មភាពអនាធិបតេយ្យនៃការទន្រ្ទានកាប់រានព្រៃឈើ និងការបង្ខាំងដីទុក ដោយធានាថា សិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធានជាទ្រព្យសម្បត្តិសម្ងហភាពតាមបែបប្រពៃណីដីធ្លី ព្រៃឈើ និងផ្លូវទឹក នឹងមិនត្រូវបានដកហូតពីសំណាក់ក្រុមមនុស្សថ្មីណាមួយឡើយ ។

---

46 តឹក វណ្ណារ៉ា, "ការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គ និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច" (សិក្ខាសាលាថ្នាក់ជាតិ, សណ្ឋាគារហ៊ីម៉ាវ៉ារី, ២៩-៣០ មេសា ២០១៨)។

47 តឹក វណ្ណារ៉ា, "ការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គ និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច" (សិក្ខាសាលាថ្នាក់ជាតិ, សណ្ឋាគារហ៊ីម៉ាវ៉ារី, ២៩-៣០ មេសា ២០១៨)។

៤.ការថែរក្សាភាពសំបូរបែបនៃវប្បធម៌ ទំនៀមទម្លាប់ប្រ ប្រពៃណីល្អ ក្នុងប្រទេសកម្ពុជា ដោយអនុញ្ញាតឲ្យសហគមន៍ជនជាតិដើមភាគតិច គ្រប់គ្រងដីធ្លីក្នុងសហគមន៍តាមប្រពៃណីរបស់ខ្លួនឲ្យមាននិរន្តភាព ។[48]

[48] គោលនយោបាយជាតិស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច, ២៤ មេសា ២០០៩, ២។

# ជំពូកទី២

# ការយល់ដឹងគតិយុត្តលើសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ខេត្តក្រចេះ

## ២.១.ទិដ្ឋភាពទូទៅនៃសហគមន៍ក្នុងខេត្តក្រចេះ

ខេត្តក្រចេះ គឺជាខេត្តមួយក្នុងចំណោមខេត្តទាំងបួនដែលស្ថិតនៅប៉ែកឦសាន្តនៃប្រទេសកម្ពុជា ហើយមានផ្ទៃក្រឡាសរុប ១១០៩៤គម$^2$ និងមានទីតាំងលាតសន្ធឹងតាមបណ្តោយដងទន្លេមេគង្គ ដែលមានព្រំប្រទល់ខាងជើងជាប់ខេត្តស្ទឹងត្រែង ខាងកើតជាប់ខេត្តមណ្ឌលគិរី ខាងលិចជាប់ខេត្តកំពង់ធំ និងកំពង់ចាម ខាងត្បូងជាប់ខេត្តត្បូងឃ្មុំ និងវៀតណាម។ ក្នុងការធ្វើដំណើរពីរាជធានីភ្នំពេញ តាមផ្លូវគោកមានចម្ងាយ ៣៤០ គីឡូម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ៧ និងតាមផ្លូវទឹកមានចម្ងាយ ២២០ គីឡូម៉ែត្រ តាមបណ្តោយដងទន្លេមេគង្គ។[49] កាលពីសម័យដើមខេត្តនេះមានជនជាតិដើមភាគតិចរស់នៅច្រើន ហើយបច្ចុប្បន្ននៅតាមបណ្តាស្រុកមួយចំនួននៃខេត្តក្រចេះនេះក៏មានជនជាតិដើមភាគតិចចំនួន ៧អម្បូរ ខុសៗគ្នាកំពុងរស់នៅផងដែរ ដែលមានដូចជា៖ ព្នង គួយ ស្អៀង មិល ក្រោល ថ្មូន និងខោញ។ គិតត្រឹមឆ្នាំ២០១៨ ខេត្តក្រចេះមានប្រជាជនជាជនជាតិដើមភាគតិចសរុបចំនួន ៤០៧,២៨៤នាក់ គិតជាគ្រួសារមានចំនួន ៩០,៦២៥គ្រួសារ ដែលក្នុងនោះជនជាតិព្នងមានចំនួន ៣,៤៨៧គ្រួសារ ជនជាតិគួយមានចំនួន ២,៣៦៨គ្រួសារ ជនជាតិស្អៀងមានចំនួន ២,៣៦៧គ្រួសារ ជនជាតិមិលមានចំនួន ១,០១៦គ្រួសារ ជនជាតិក្រោលមានចំនួន ៩៥៩ គ្រួសារ ជនជាតិថ្មូនមានចំនួន ១៩១គ្រួសារ និងជនជាតិខោញមានចំនួន ២០៩គ្រួសារ។[50] ម្យ៉ាងវិញទៀត បច្ចុប្បន្នកំណើននៃប្រជាជនជនជាតិដើមភាគតិចមានការកើនឡើងជាលំដាប់ ដូច្នេះហើយតម្រូវការនៃការរស់នៅ និងតម្រូវការនៃការប្រើប្រាស់ដីសម្រាប់ធ្វើជាលំនៅដ្ឋាន ដីចម្ការវិលជុំ ដីព្រៃអារក្ស និងព្រៃកប់ខ្មោចក៏ជាតម្រូវការចាំបាច់បន្ថែមផងដែរ។

[49] https://km.wikipedia.org/wiki/ (ចូលទស្សនាថ្ងៃទី ២០ មិថុនា ២០១៩)

[50] ឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ (ក្រចេះ៖ មន្ទីរផែនការខេត្ត, មីនា ២០១៩)។

## ២.២.ការអនុវត្តសិទ្ធិគ្រប់គ្រង និងសិទ្ធិប្រើប្រាស់ដីជាសមូហភាព

### ២.២.១.សមាជិកសហគមន៍

សហគមន៍មួយគឺមានគ្រួសារច្រើនដែលជាសមាជិករបស់សហគមន៍ ក្នុងនោះដែរអ្នកដែលចាត់ទុកជាសមាជិកសហគមន៍ គឺជាបុគ្គលដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសមាជិកសហគមន៍ ហើយមានចែងក្នុងលក្ខន្តិកៈសហគមន៍ ដែលទទួលស្គាល់ពីគណៈកម្មាធិការសហគមន៍ ក្រុមប្រឹក្សាឃុំ និងក្រសួងមហាផ្ទៃ។[51] សមាជិកទាំងអស់មានសិទ្ធិដូចគ្នាក្នុងការទទួលចំណែកដី ឬបានផលប្រយោជន៍ពីសហគមន៍។[52] លើសពីនេះទៅទៀតសមាជិកសហគមន៍ទាំងអស់គឺជាម្ចាស់កម្មសិទ្ធិសមូហភាព ហើយអ្នកដែលតំណាងឲ្យម្ចាស់កម្មសិទ្ធិសមូហភាពសហគមន៍ គឺជាប្រធានគណៈកម្មាធិការសហគមន៍ដែលមានក្រសួងមហាផ្ទៃទទួលស្គាល់។[53] សមាជិកទាំងអស់របស់សហគមន៍មានសិទ្ធិប្រើប្រាស់អាស្រ័យផលលើចំណែកដីរបស់ខ្លួនដូចជា៖ ដាំដំណាំបន្លែចម្រុះ កាប់ចម្ការវិលជុំតាមបែបប្រពៃណី ធ្វើស្រែ រកអនុផលព្រៃឈើ និងថែរក្សាការពារធនធានដែលមានក្នុងសហគមន៍និងមានសិទ្ធិចាត់ចែងទៅលើកម្មសិទ្ធិដែលជាចំណែកដីរបស់ខ្លួនបានតែក្នុងសហគមន៍របស់ខ្លួនប៉ុណ្ណោះដូចជា៖ ការផ្ទេរ ការលក់ ការទិញ ការជួលនិងការដោះដូរ ហើយត្រូវមានការឯកភាពពីសាមីខ្លួនឬក្រុមគ្រួសារ និងមានការដឹងលឺពីសមាជិកសហគមន៍ គណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរពាក់ព័ន្ធ ប៉ុន្តែគ្មានសិទ្ធិក្នុងការលក់ ផ្ទេរ ឬប្រគល់ទៅឲ្យអ្នកដែលមិនមែនជាសមាជិកក្នុងសហគមន៍បានទេ ទោះក្នុងរូបភាពណាក៏ដោយ។[54] ម្យ៉ាងវិញទៀតចំពោះម្ចាស់ចំណែកដីគាត់មានសិទ្ធិផ្ទេរចំណែកដីទៅឲ្យសមាជិកក្នុងសហគមន៍របស់ខ្លួនបានលុះត្រាតែម្ចាស់ចំណែកដីមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ដោយការផ្ទេរចំណែកដីនេះផងដែរត្រូវធ្វើឡើងដោយមានកិច្ចសន្យាជាលាយល័ក្ខអក្សរ ហើយត្រូវតម្កល់ទុកឯកសារនៃកិច្ចសន្យានៅគណៈកម្មាធិការសហគមន៍ សាលាឃុំ

[51] បទបញ្ជាផ្ទៃក្នុងស្ដីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាពសហគមន៍ជនជាតិដើមភាគតិចព្នង ភូមិពន្ធជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ, ប្រការ៣។

[52] បទបញ្ជាផ្ទៃក្នុងស្ដីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាពសហគមន៍ជនជាតិដើមភាគតិចព្នង ភូមិពន្ធជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ, ប្រការ៣។

[53] បទបញ្ជាផ្ទៃក្នុងស្ដីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាពសហគមន៍ជនជាតិដើមភាគតិចព្នង ភូមិពន្ធជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ, ប្រការ១៩។

[54] បទបញ្ជាផ្ទៃក្នុងស្ដីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាពសហគមន៍ជនជាតិដើមភាគតិចព្នង ភូមិពន្ធជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ, ប្រការ២០។

និងមិនត្រូវធ្វើឲ្យប៉ះពាល់វប្បធម៌ប្រពៃណី និងទំនៀមទំលាប់របស់សហគមន៍ឡើយ។[55] លើសពីនេះទៅទៀតសមាជិកក្នុងសហគមន៍អាចមានសិទ្ធិលក់ដី ដែលជាចំណែករបស់ខ្លួនទៅឲ្យសមាជិកក្នុងសហគមន៍ជាមួយគ្នាបានដោយលក់បានត្រឹមតែ២ហិចតាប៉ុណ្ណោះមិនអាចលក់ទាំងអស់នៃចំណែកដីរបស់ខ្លួនបានទេ ហើយសមាជិកក្នុងសហគមន៍ក៏អាចមានសិទ្ធិទិញចំណែកដីពីសមាជិកក្នុងសហគមន៍តែមួយបានដូចគ្នាដែរតែទិញបានត្រឹមតែ២ហិចតាផងដែរ។[56]

### ២.២.២.ការកំណត់ព្រំប្រទល់ និងតំបន់ប្រើប្រាស់ដីសហគមន៍

ការកំណត់ព្រំប្រទល់ដី គឺជាការចាំបាច់ណាស់សម្រាប់ប្រជាពលរដ្ឋក៏ដូចជាសហគមន៍ជនជាតិដើមភាគតិចដើម្បីបញ្ជាក់អំពីព្រំដីពីសហគមន៍មួយទៅសហគមន៍មួយទៀត និងដើម្បីជៀសវាងពីការទន្ទ្រានដីដោយការមិនបានកំណត់ព្រំដីច្បាស់លាស់ ដូច្នេះហើយទើបសហគមន៍នីមួយៗធ្វើការកំណត់ព្រំដីបញ្ជាក់ពីព្រំប្រទល់សហគមន៍របស់ខ្លួន ក្នុងនោះដែររាល់ការកំណត់ព្រំប្រទល់ដីក៏ត្រូវមានការចូលរួមឯកភាពពីភាគីពាក់ព័ន្ធដូចជាសហគមន៍ខ្លួនឯង សហគមន៍ជិតខាង និងអាជ្ញាធរមូលដ្ឋាន ឬអ្នកពាក់ព័ន្ធនានាដែលមានដូចជា៖ គណៈកម្មាធិការ សមាជិកសហគមន៍ ចាស់ទុំសាមី និងអ្នកជិតខាង មេភូមិសាមី និងមេភូមិជិតខាង ក្រុមប្រឹក្សាឃុំសាមី និងក្រុមប្រឹក្សាឃុំជិតខាង អាជ្ញាធរស្រុក ភូមិបាលស្រុក សង្កាត់រដ្ឋបាលព្រៃឈើ មន្ទីរបរិស្ថាន មន្ទីរកសិកម្ម និងមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់។[57] ជាក់ស្តែងដូចសហគមន៍ជនជាតិដើមភាគតិចព្នងដែលជាសហគមន៍មួយក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចដទៃទៀតដែលកំពុងតែរស់នៅក្នុងទឹកដីនៃខេត្តក្រចេះ ហើយក៏ជាសហគមន៍មួយដែលបានចុះបញ្ជីដីធ្លីត្រឹមត្រូវតាមច្បាប់កំណត់ និងបានកំណត់ព្រំប្រទល់ដីច្បាស់លាស់។

ក្នុងនោះផងដែរសហគមន៍ជនជាតិដើមភាគតិចមានទីតាំងភូមិសាស្ត្រស្ថិតក្នុងភូមិពន្ធជា ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ដែលមានព្រំប្រទល់ខាងជើងជាប់ភូមិកោះខ្ញែ ឃុំអូរគ្រៀង ស្រុកសំបូរ (ដែលកំណត់សំគាល់ព្រំដោយ ព្រៃជំនឿអ្នកតាញ៉ាហើ{សំគាល់ដោយឈើទាល} គម្លោតស្រែប្រិយ ស្រែពូឌិច និងនៅតាមមាត់ទន្លេជាប់បង្គោលព្រំសហគមន៍នេសាទ) ខាងត្បូងជាប់

---

[55] បទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាពសហគមន៍ជនជាតិដើភាគតិចព្នង ភូមិពន្ធជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ, ប្រការ២៦។

[56] បទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាពសហគមន៍ជនជាតិដើភាគតិចព្នង ភូមិពន្ធជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ, ប្រការ២៨-២៩។

[57] បទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាពសហគមន៍ជនជាតិដើភាគតិចព្នង ភូមិពន្ធជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ, ប្រការ១៦។

ភូមិអូរកក់ ឃុំអូរគ្រៀង ស្រុកសំបូរ (ដែលកំណត់សំគាល់ព្រំដោយពាមអូរគ្រៀង) ខាងកើតជាប់ភូមិអូរគ្រៀង និងភូមិអូរព្រះ ឃុំអូរគ្រៀង ស្រុកសំបូរ (ដែលមានកំណត់សំគាល់ព្រំដោយអូរឡង់ ពាមក្រសាំង និងថ្មដា) និងខាងលិចជាប់ភូមិអូរក្រសាំង ឃុំបឹងចារ ស្រុកសំបូរ (ដែលកំណត់សំគាល់ព្រំដោយកោះរងា និងទន្លេមេគង្គត្រង់ចំណុចអន្លង់ត្រឡោក)។[58]

ចំពោះប្រភេទដីដែលសហគមន៍ជនជាតិដើមភាគតិចព្នង ភូមិពន្ទជា ប្រើប្រាស់សព្វថ្ងៃមានដូចជា៖ ដីលំនៅដ្ឋានមាន ១កន្លែងគឺ ភូមិពន្ទជា ដីបំរុងទុកមាន ៥កន្លែងគឺ ព្រៃអូរលូង កោះក្រឹង កោះអរ កោះតាចាន់តូច និងកោះតាចាន់ធំ ព្រៃអារក្ស មាន ៤កន្លែងគឺ កំពតង្វ កំពតស្រែប្រី អូរលូង និងញ៉ាហី ព្រៃការពារ មាន ១កន្លែងគឺ សហគមន៍ព្រៃឈើ ព្រៃកប់ខ្មោច មាន ៤កន្លែងគឺ កោះសន្ទុប អូរពន្ទជា អន្លង់អភិរក្ស មាន ៧កន្លែងគឺ យាយគង ព្រះទ្វារ អន្លង់តាណាយ អន្លង់គគី អន្លង់មេទុម អន្លង់គគីរ និងអន្លង់ត្រលោក ដីសាធារណៈរបស់រដ្ឋ មាន គឺផ្លូវ អណ្តូងស្នប់ អូរ ភ្នំ លូស្ពាន សាលារៀន និងដីព្រៃ សាលាឆទាន កុដិ ដីស្រែ ដីសហគមន៍ព្រៃឈើ ដីព្រៃឫស្សី ដីលិចទឹក និងដីទួលសុវត្ថិភាព។[59]

## ២.៣.ប្រភេទដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាព

កម្មសិទ្ធិដីសមូហភាព គឺជាដីដែលជនជាតិដើមភាគតិចប្រើប្រាស់ជារួមក្នុងសហគមន៍ ហើយសហគមន៍អាចស្នើសុំក្នុងការយកដីរបស់ពួកគាត់ទៅចុះបញ្ជីដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិ។ លើសពីនេះទៀតដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់ សហគមន៍ជនជាតិដើមភាគតិចមាន៖

១- ដីឯកជនរបស់រដ្ឋ៖
- លំនៅឋាន ឬដីដែលសហគមន៍បានរៀបចំនិវេសដ្ឋាន
- ដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី មានដីដាំដុះជាក់ស្តែង ដីស្រែចម្ការ និង

២- ដីសាធារណៈរបស់រដ្ឋ ដែលបានចុះបញ្ជីរួចហើយជាមួយរដ្ឋ៖
- ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ ដែលបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល និងមានការព្រមព្រៀងពីអ្នកជិតខាង

[58] បទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាពសហគមន៍ជនជាតិដើភាគតិចព្នង ភូមិពន្ទជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ, ប្រការ១៨។
[59] បទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាពសហគមន៍ជនជាតិដើភាគតិចព្នង ភូមិពន្ទជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ, ប្រការ១៨។

- ដីព្រៃអារក្ស ដែលមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពី ០៧ (ប្រាំពីរ) ហិចតា
- ដីកប់ខ្មោច ដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពី ០៧ (ប្រាំពីរ) ហិចតា។[60]

## ២.៤.នីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍

សហគមន៍ជនជាតិដើមភាគតិចទាំងអស់ដែលមានដីធ្លីមិនថាដីលំនៅដ្ឋាន ឬដីស្រែចម្ការកាលណាមិនមានការយល់ដឹងពីនីតិវិធីនៃការចុះបញ្ជីដីធ្លី ហើយមិនបានចុះបញ្ជីដីធ្លីរបស់ខ្លួនទៀតនោះនឹងធ្វើការកាន់កាប់ពុំធានានូវសុវត្ថិភាព និងមិនមានភាពស្របច្បាប់ក្នុងការកាន់កាប់ផងដែរ។ បើសហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីដីធ្លីគឺមានសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីធានានូវសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងការពារកម្មសិទ្ធិសម្ធូហភាពរបស់សហគមន៍។

### ២.៤.១.លក្ខខណ្ឌនៃការចុះបញ្ជី

ដើម្បីឲ្យសហគមន៍ជនជាតិដើមភាគតិចទទួលបាននូវកម្មសិទ្ធិដីធ្លីសម្ធូហភាព គឺត្រូវបំពេញនូវលក្ខខណ្ឌ ៣សំខាន់ៗដែលមានដូចជា៖ ទី១ គឺលិខិតទទួលស្គាល់ថាជាសហគមន៍ជនជាតិដើមភាគតិចចេញដោយក្រសួងអភិវឌ្ឍន៍ជនបទ ទី២ គឺការចុះបញ្ជីសហគមន៍ជានីតិបុគ្គលស្របច្បាប់ដែលបានចុះបញ្ជីដោយក្រសួងមហាផ្ទៃ ទី៣ គឺចុះវាស់វែងដី និងចេញប័ណ្ណកម្មសិទ្ធិនៃការប្រើប្រាស់ដីដោយក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់។[61]

### ២.៤.២.ដំណើរការនៃការចុះបញ្ជី

ក្នុងដំណើរការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវមានភាពងាយស្រួលទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេស និងត្រូវតែមានតម្លាភាព ដោយមានការចូលរួមពីតំណាងសហគមន៍ សមាជិកផ្សេងៗនៃសហគមន៍ផ្ទាល់ និងសមាជិកនៃសហគមន៍ជិតខាង ក្នុងការកំណត់ទីតាំងព្រំប្រទល់ដីសហគមន៍នីមួយៗ និងការបិទផ្សាយឯកសារជាសាធារណៈ។ ដើម្បីឲ្យការចុះបញ្ជីកម្មសិទ្ធិដីសម្ធូហភាពកាន់តែមានប្រសិទ្ធិភាព គឺប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី ឬតំណាងសហគមន៍ជនជាតិដើមភាគតិចនិមួយៗ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីរបស់សហគមន៍ខ្លួនដែលបានកាន់កាប់ ព្រមទាំងឯកសារផ្សេងៗទៀតត្រូវភ្ជាប់មកជាមួយ ទៅ

---

[60] អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, លេខ៨៣អនក្រ/បក, ០៩ មិថុនា ២០០៩, មាត្រា ៦។

[61] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានៅតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសម្ធូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ១១។

ការិយាល័យភូមិបាលស្រុក ឬមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ចំពោះសំណុំលិខិតស្នើសុំចុះបញ្ជីដីសហគមន៍របស់សហគមន៍ជនជាតិដើមភាគតិច មានដូចតទៅ៖

- ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍មានផ្តិតមេដៃប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី
- លិខិតប្រគល់សិទ្ធិជូនសមាជិកគណៈកម្មាធិការសហគមន៍ណាមួយជាតំណាងសហគមន៍ ក្នុងដំណើរការផ្តល់ព័ត៌មាន ការបំពេញទម្រង់បែបបទក្នុងការចុះបញ្ជីដីសហគមន៍តាមនីតិវិធីជាធរមាន ប្រសិនបើប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណីមិនអាចចូលរួមបាន
- លក្ខន្តិកៈរបស់សហគមន៍ និងបញ្ជីរាយនាមសមាជិកសហគមន៍មានសេចក្តីបញ្ជាក់ពីចៅសង្កាត់ មេឃុំ
- បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ទាក់ទងនឹងរបៀបគ្រប់គ្រង និងការប្រើប្រាស់ដីជាសម្ូហភាព
- លិខិតជូនដំណឹងស្តីពីការយល់ព្រមឲ្យចុះបញ្ជីសហគមន៍ដោយក្រសួងមហាផ្ទៃ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់ ឃុំស្តីពីការតែងតាំងគណៈកម្មាធីការសហគមន៍ និង
- រាល់ឯកសារពាក់ព័ន្ធ និងដីដែលស្នើសុំចុះបញ្ជីប្រសិនបើមាន។[62]

ម៉្យាងវិញទៀតមិនត្រឹមតែមានពាក្យស្នើសុំប៉ុណ្ណោះទេ គឺត្រូវមានឯកសារភ្ជាប់អមជាមួយនឹងពាក្យស្នើសុំនោះមកជាមួយបន្ថែមផងដែរ ដែលឯកសារនោះរួមមាន៖

- លិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចដោយក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតពីក្រសួងមហាផ្ទៃដែលទទួលស្គាល់សហគមន៍ជានីតិបុគ្គល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ ឯកភាពទៅលើការតែងតាំងពីគណៈកម្មាធិការសហា គមន៍
- លក្ខន្តិកៈសហគមន៍
- បញ្ជីរាយនាមសមាជិកសហគមន៍ ដោយមានការផ្ទៀងផ្ទាត់ទៅលើបញ្ជីរាយនាមនោះពីសំណាក់លោកមេឃុំ
- បទបញ្ជាផ្ទៃក្នុងសហគមន៍ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដី និងយន្តការដោះស្រាយជម្លោះ

[62] អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, លេខ៨៣អនក្រ/បក, ០៩ មិថុនា ២០០៩, មាត្រា ៨។

- ផែនទីបឋមដែលបង្ហាញអំពីទីតាំង ទំហំ និងព្រំប្រទល់របស់ដីសហគមន៍
- ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច
- លិខិតពីប្រធានគណៈកម្មាធិការសហគមន៍ ដែលអនុញ្ញាតឲ្យមានការផ្ទេរតួនាទីពីប្រធានទៅឲ្យអនុប្រធាន នៅក្នុងករណីដែលប្រធានមិនអាចបំពេញភារកិច្ចបាន។[63]

ក្រោយពីបានទទួលពាក្យស្នើសុំចុះបញ្ជី ប្រសិនបើទីតាំង ទំហំ និងព្រំប្រទល់សហគមន៍មានការឯកភាពពីអ្នកជិតខាង អាជ្ញាធររដ្ឋបាល និងមិនមានទំនាស់ ឬមានទំនាស់តែត្រូវបានដោះស្រាយរួចរាល់ហើយ នោះប្រធានមន្ទីរនិងធ្វើលិខិតស្នើទៅអភិបាលនៃគណៈអភិបាលខេត្តចេញលិខិតបង្កក់ការទិញ លក់ ផ្ទេរកម្មសិទ្ធិដីក្នុងបរិវេណដែលបានស្នើសុំចុះបញ្ជីជាដីសហគមន៍ជនជាតិដើមភាគតិច។ បន្ទាប់មកការិយាល័យភូមិបាលស្រុកត្រូវលើកសំណើរជូនអភិបាលស្រុក ដើម្បីចេញសេចក្ដីជូនដំណឹងជាសាធារណៈក្នុងរយៈពេល២០ថ្ងៃយ៉ាងតិច មុនពេលកាលបរិច្ឆេទចុះកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ។[64]

សេចក្ដីជូនដំណឹងត្រូវបិទផ្សាយជាសាធារណៈនៅកន្លែងងាយមើលឃើញដូចជាៈ ទីស្នាក់ការភូមិ សាលាឃុំ ទីប្រជុំជន និងទីតាំងដីដែលសហគមន៍ស្នើសុំក្រោយពីបានបិទផ្សាយរយៈពេល ២០ថ្ងៃ ពុំមានការជំទាស់ ឬតវ៉ាទេ នោះមន្ត្រីត្រូវអនុវត្តបន្ត។[65] ការងារវាស់វែង គឺក្រុមការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចធ្វើការកំណត់អត្តសញ្ញាណកម្មដីរដ្ឋ កំណត់ព្រំ និងវាស់វែងដីសហគមន៍ជនជាតិដើមភាគតិចដែលមាន៥ប្រភេទដូចជាៈ ដីលំនៅដ្ឋាន ឬដីសហគមន៍បានរៀបនិវេសនដ្ឋាន ដីដែលសហគមន៍ប្រកបរបរកសិកម្មតាមបែបប្រពៃណី ដីបំរុងចាំបាច់ក្នុងការដូរវេនដំណាំ ដែលទទួលស្គាល់ដោយអាជ្ញាធរ ឬពីអ្នកជិតខាង ដីព្រៃអារក្ស (មិនលើសពី ៧ហិចតា) ដីកប់ខ្មោច (មិនលើសពី ៧ហិចតា) ហើយសហគមន៍ត្រូវចូលរួមបង្ហាញនូវទីតាំង ព្រំប្រទល់ និងទំហំនៃចំណែកដីផ្សេងៗដែលសហគមន៍បានកាន់កាប់ និងកំពុងប្រើប្រាស់ដល់ក្រុមការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ក្នុងនោះដែរមន្ត្រីជំនាញត្រូវបញ្ចូលទិន្នន័យដែលប្រមូលបានទៅក្នុង

[63] សៀវភៅណែនាំស្ដីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ៣២-៣៣។

[64] អនុក្រឹត្យស្ដីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, លេខ៨៣អនក្រ/បក, ០៩ មិថុនា ២០០៩, មាត្រា ៩។

[65] សៀវភៅណែនាំស្ដីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ៣៧។

កុំព្យូទ័រដើម្បីកសាងបញ្ជីឈ្មោះម្ចាស់ដី និងប្លង់ផែនទីក្បាលដីព្រមទាំងរៀបចំឯកសារដើម្បីពិនិត្យឲ្យបានត្រឹមត្រូវ និងត្រៀមយកទៅធ្វើការបិទផ្សាយ។[66]

ម្យ៉ាងវិញទៀតទិន្នន័យដែលប្រមូលបាន មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីនឹងធ្វើសំណើរទីអភិបាលស្រុក ដើម្បីចេញសេចក្តីជូនដំណឹង ស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការ វិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិចរយៈពេល៣០ថ្ងៃ ដោយគិតទាំងថ្ងៃបុណ្យជាតិ និងថ្ងៃឈប់សម្រាក ហើយការបិទផ្សាយរយៈពេល៣០ថ្ងៃ គឺដើម្បីឲ្យម្ចាស់ដីសហគមន៍ ស្ថាប័នពាក់ព័ន្ធ និងសមាជិកគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តទាំងអស់ចូលរួមពិនិត្យ និងធ្វើការតវ៉ាករណីមានការខុសឆ្គង។[67] ចំពោះករណីទីតាំង ទំហំ និងព្រំប្រទល់ដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលស្នើសុំចុះបញ្ជីនៅមិនទាន់មានការឯកភាពពីអ្នកជិតខាង ឬអាជ្ញាធររដ្ឋបាល គឺត្រូវរៀបចំកិច្ចដំណើរការតាមរយៈយន្តការ និងនីតិវិធីដូចតទៅៈ

- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ត្រូវលើកសំណើទៅអភិបាលក្រុង ស្រុក ដែលជាប្រធានក្រុមការងារដីរដ្ឋថ្នាក់ ក្រុង ស្រុក ដើម្បីដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ នៅតំបន់ដែលសហគមន៍ស្នើសុំចុះបញ្ជីដី។
- បន្ទាប់ពីទទួលបានសំណើ អភិបាលក្រុង ស្រុក ត្រូវពិនិត្យ និងលើកយោបល់ ជូនអភិបាលខេត្តជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្នុងរយៈពេលមិនលើស

  ពី ១៥ (ដប់ប្រាំ) ថ្ងៃ សុំឲ្យក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុកចុះធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីរបស់សហគមន៍ នៅតំបន់ដែលសហគមន៍ស្នើសុំចុះបញ្ជី។
- អភិបាលខេត្តត្រូវចាត់តាំងក្រុមការងារដីរដ្ឋថ្នាក់ ក្រុង ស្រុក ប្រសិនបើមិនទាន់ចាត់តាំងដើម្បីអនុវត្តដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានសុំចុះបញ្ជី ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា ៦និងមាត្រា ៧ នៃអនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ មាត្រា ៦ និងមាត្រា ៧។[68]

---

[66] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ៣៧-៣៨។

[67] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ៣៨។

[68] អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, លេខ៨៣អនក្រ/បក, ០៩ មិថុនា ២០០៩, មាត្រា ១០។

ក្នុងករណីដែលមានសហគមន៍ ឬសមាជិកសហគមន៍ជនជាតិដើមភាគតិចណាមួយរកឃើញកំហុសឆ្គង ឬទំនាស់ទៅនឹងឯកសារវិនិច្ឆ័យដែលកំពុងបិទផ្សាយសាធារណៈនោះ នោះសហគមន៍ ឬសមាជិកសហគមន៍ជនជាតិដើមភាគតិចនោះ អាចដាក់ពាក្យប្ដឹង ឬស្នើសុំជាលាយលក្ខអក្សរ ឲ្យមន្ត្រីបច្ចេកទេសធ្វើការកែប្រែ ឬផ្អាកការបិទផ្សាយជាបណ្ដោះអាសន្នសិន។[69] បន្ទាប់ពីការបញ្ចប់ការបិទផ្សាយជាសាធារណៈនូវការវិនិច្ឆ័យ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីត្រូវធ្វើរបាយការណ៍ស្ដីពីលទ្ធផលនៃការបិទផ្សាយដាក់ជូនអភិបាលនៃគណៈអភិបាលខេត្តពិនិត្យ និងសម្រេចលើរបាយការណ៍ និងឯកសារវិនីច្ឆ័យដើម្បីផ្ដល់វិញ្ញាបនប័ត្រសម្គាល់កម្មសិទ្ធិដី សមូហភាពជូនសហគមន៍ជនជាតិដើមភាគតិច ដើម្បីធ្វើការសម្រេចនេះបាន អភិបាលខេត្តត្រូវធ្វើសំណើទៅនាយកមន្ត្រីតាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ ស្នើសុំអនុបយោគសម្រាប់ប្រទានកម្ម ចំពោះដីលំនៅឋាន និងដីកសិកម្ម ដែលមានទីតាំងស្ថិតនៅក្នុងចំណែកដីសាធារណៈរបស់រដ្ឋ។[70]

dក្រោយពីបានទទួលលិខិតស្នើសុំធ្វើអនុបយោគ ពីសំណាក់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងធ្វើលិខិតពីរដាច់ដោយឡែកពីគ្នាផ្ញើទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំការពិនិត្យ និងយល់ស្របលើសំណើសុំអនុបយោគដី ដែលសហគមន៍ជានជាតិដើមភាគតិចបានស្នើសុំចុះបញ្ជីជាដីសហគមន៍ជនជាតិដីភាគតិច។[71]

ប្រភេទដីដែលស្នើសុំការពិនិត្យ និងយល់ស្របពីក្រសួង បរិស្ថាន រួមមានដីស្ថិតនៅក្នុងតំបន់អភិរក្សសត្វព្រៃ តំបន់ការពារ និងតំបន់របៀងបរិស្ថាន។ល។ ឯប្រភេទដីដែលត្រូវស្នើសុំការពិនិត្យ និងយល់ស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមានដីព្រៃសហគមន៍ និងដីកសិកម្ម និងដីគម្របព្រៃឈើ។ បន្ទាប់ពីក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឆ្លើយតបទៅនឹងលិខិតស្នើសុំការពិនិត្យ និងការយល់ស្របហើយនោះ ក្រសួងរៀបចំដែនដី

[69] សៀវភៅណែនាំស្ដីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ៣៨។

[70] សៀវភៅណែនាំស្ដីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ៣៩។

[71] សៀវភៅណែនាំស្ដីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ៣៩។

នគរូបនីយកម្ម និងសំណង់ ធ្វើលិខិតមួយទៀតទៅកាន់រាជរដ្ឋាភិបាលដើម្បីស្នើសុំអនុបយោគ និង ប្រទានកម្មដីរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចតាមការស្នើសុំរបស់សហគមន៍។[72]

បន្ទាប់មកទៀតមន្ទីររៀបចំដែនដី នគរូមនីយកម្ម សំណង់ និងសុរិយោដី រៀបចំបោះពុម្ព វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាព ចុះហត្ថលេខា និងចែកជូនសហគមន៍ដោយមានបញ្ជាក់ ឈ្មោះសហគមន៍ ទីតាំងសហគមន៍ លេខយោងទៅរកប្លង់រួម ដែលចង្អុលនូវទីតាំង ទំហំ ព្រំប្រទល់ និយាមការនៃចំណែកដីដែលជាកម្មសិទ្ធិសមូហភាព មានបញ្ជាក់ប្រភេទនៃការប្រើប្រាស់ដីនិង កំណត់សម្គាល់ផ្សេងៗ។[73] គួរកត់សម្គាល់ថាបច្ចុប្បន្នសហគមន៍ជនជាតិដើមភាគតិចនៅខេត្ត ក្រចេះមានចំនួន ៤ ប៉ុណ្ណោះដែលបានចុះបញ្ជីដីត្រឹមត្រូវ និងស្របតាមនីតិវិធីច្បាប់។[74]

[72] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ៣៩។

[73] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ៣៩។

[74] យិន បូទុម (អនុប្រធានមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តក្រចេះ), បទសម្ភាសដោយ និស្សិត ឈិន រ៉េក្រ្កវត្តី និងកេង គីមឡេង, " ១៨ មីនា ២០១៩ " ។

# ជំពូកទី៣

# បញ្ហាប្រឈមនៃការបាត់បង់ដីរបស់សហគមន៍ជនជាតិដើមភាគតិច

## ៣.១.កត្តាសហគមន៍

### ៣.១.១.កង្វះខាតការយល់ដឹងអំពីសិទ្ធិក្នុងការប្រើប្រាស់ដីសម្ហូហភាព

សមាជិកសហគមន៍បានបញ្ចេញឲ្យដឹងអំពីកង្វះខាតការយល់ដឹងក្នុងការប្រើប្រាស់ដីជាសម្ហូហភាពនៅមានភាពស្មុគស្មាញដែលនាំឲ្យមានការបាត់បង់ដីធ្លី។ កម្រិតនៃការយល់ដឹងក្នុងចំណោមសហគមន៍នៅមានកម្រិត ពួកគាត់មិនទាន់យល់ច្បាស់នៅអ្វីដែលហៅថាជាសិទ្ធិ ។ ដូច្នេះការប្រើប្រាស់ដីមិនសមស្របទៅតាមសិទ្ធិរបស់ពួកគាត់ អាចប្រឈមអោយមានការរំលោភបំពាន។ ប៉ុន្តែប្រសិនបើពួកគាត់ទទួលបានការបណ្តុះបណ្តាលច្រើនអំពីសិទ្ធិរបស់ពួកគាត់ ពួកគាត់អាចនឹងត្រៀមខ្លួនក្នុងការតស៊ូមតិប្រឆាំងដើម្បីសិទ្ធិទាំងនោះនិងការពារដីរបស់ខ្លួន។[75] ដូច្នេះហើយ ការបណ្តុះបណ្តាលនិងការផ្តល់ព័ត៌មានបន្ថែមអំពីសិទ្ធិដីធ្លីអាចនឹងធានាថាសហគមន៍ជនជាតិដើមភាគតិចបានត្រៀមខ្លួនបានល្អក្នុងការការពារដីរបស់ពួកគេ។[76]

### ៣.១.២.កង្វះខាតចំណេះដឹងក្នុងការយកដីទៅចុះបញ្ជី

ការយកដីទៅចុះបញ្ជីរបស់សហគមន៍ជនជាតិដើមភាគតិច រួចទទួលបានប័ណ្ណកម្មសិទ្ធិគឺជាផ្នែកមួយដ៏សំខាន់សម្រាប់សហគមន៍ជនជាតិដើមភាគតិចក្នុងការការពារដីរបស់ពួកគាត់ពីការទន្ទ្រានដី ឬ រំលោភបំពានពីសំណាក់ក្រុមហ៊ុន។ ដោយហេតុថា នីតិវិធីការចុះបញ្ជីដីធ្លីរបស់សហគមន៍របស់ពួកគាត់នៅមានលក្ខណៈស្មុគស្មាញពេកទើបធ្វើឲ្យពួកគាត់មានការពិបាកក្នុងការយកដីទៅចុះបញ្ជី។[77] វាច្បាស់ណាស់ប្រសិនបើគ្មានជំនួយពីរាជរដ្ឋាភិបាល ឬ អង្គការសង្គមស៊ីវិលទេ សហគមន៍មិនអាចដំណើរការក្នុងទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីទេ ដោយសារតែពួកគាត់នៅខ្វះ

---

[75] មជ្ឈមណ្ឌលសិទ្ធិមនុស្ស " *ការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ហូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា* ", (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, កុម្ភៈ ២០១៦), ៤៤-៤៥។

[76] មជ្ឈមណ្ឌលសិទ្ធិមនុស្ស " *ការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ហូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា* ", (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, កុម្ភៈ ២០១៦), ៤៥។

[77] យិន បូទុម (អនុប្រធានមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តក្រចេះ), បទសម្ភាសដោយ និស្សិត ឈិន រ៉េក្រ្តវត្តី និងកេង គីមឡេង, " ១៨ មីនា ២០១៩ " ។

ចំណេះដឹងអ្វីដែលពាក់ព័ន្ធក្នុងដំណើរការនេះ។[78] ដូច្នេះការដែលមិនបានយកដីទៅចុះបញ្ជីនោះធ្វើឲ្យពួកគាត់បាត់បង់ដីរួមជាមួយនឹងទំនៀមទម្លាប់ វប្បធម៌ ប្រពៃណី និងប្រយោជន៍យ៉ាងច្រើន។

### ៣.១.៣.កង្វះខាតទំនុកចិត្តលើរដ្ឋាភិបាល

ការទុកចិត្តលើរាជរដ្ឋាភិបាល គឺជាបញ្ហាសំខាន់ចំពោះការតស៊ូក្នុងការការពារដីរបស់សហគមន៍ជនជាតិដើមភាគតិច ពីការទន្ទ្រានដី និងការគំរាមគំហែងពីសំណាក់ក្រុមហ៊ុន។[79] ពួកគាត់អាចបាត់បង់ទំនុកចិត្តដោយសារតែពួកគាត់គិតថា គាត់បានខិតខំការពារដីពីការរំលោភបំពានតែបែរជាមិនមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលទៅលើការស្ថានភាពរបស់ពួគគាត់ ដោយយកដីរបស់ពួកគាត់ទៅសម្បទានឲ្យក្រុមហ៊ុន ដូច្នេះធ្វើពួកគាត់បាត់បង់ការប្តេជ្ញាចិត្តក្នុងការការពារដីតទៅទៀត។

### ៣.១.៤.កង្វះខាតការឯកភាពក្នុងសហគមន៍

កង្វះខាតការឯកភាពក្នុងសហគមន៍ គឺជាកត្តារារាំងដល់ដំណើរការទទួលបានកម្មសិទ្ធិសមូហភាព។ [បើតាមការលើកឡើងរបស់តំណាងសហគមន៍ សមាជិកសហគមន៍មួយចំនួនបានជំទាស់នឹងដំបូន្មានរបស់ប្រធានសហគមន៍ ដោយហាមមិនឲ្យពួកគេលក់ដីទៅឲ្យអ្នកចំណូលថ្មី ឬក្រុមហ៊ុន]។[80] តែផ្ទុយទៅវិញពួកគេនៅតែលក់ដីឲ្យទៅអ្នកចំណូលថ្មី ដើម្បីដោះបន្ទុកខាងវិបត្តិហារិញ្ញវត្ថុ ដែលនេះជាទង្វើឲ្យមានការបាត់បង់ដីរបស់សហគមន៍ជនជាតិដើមភាគតិច]។[81] កង្វះការឯកភាពក្នុងសហគមន៍ជាចំណែកក្នុងការអូសបន្លាយទៅលើដំណើរនៃការទទួលបានប័ណ្ណកម្មសិទ្ធិ។ ការចង់បានប័ណ្ណកម្មសិទ្ធិឯកជនវាមានផលប្រយោជន៍សម្រាប់គ្រួសាររបស់បងប្អូនជនជាតិដើមភាគតិចមួយចំនួន ព្រោះពួកគាត់អាចយកដីទៅដាក់បញ្ចាំក្នុងការខ្ចីលុយពីធនាគារដើម្បីដោះ

[78] យិន បូទុម (អនុប្រធានមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តក្រចេះ), បទសម្ភាសដោយ និស្សិត ឈិន វរ័ក្រ្កវត្តី និងកេង គីមឡេង, " ១៨ មីនា ២០១៩ " ។

[79] មជ្ឈមណ្ឌលសិទ្ធិមនុស្ស " *ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា* ", (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, កុម្ភៈ ២០១៦), ៤៥។

[80] មជ្ឈមណ្ឌលសិទ្ធិមនុស្ស " *ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា* ", (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, កុម្ភៈ ២០១៦), ៤៦។

[81] មជ្ឈមណ្ឌលសិទ្ធិមនុស្ស " *ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា* ", (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, កុម្ភៈ ២០១៦), ៤៦។

ស្រាយជីវភាពពួកគាត់ [ដែលផ្ទុយពីប័ណ្ណកម្មសិទ្ធិដីសម្ហូភាពដែលតាមច្បាប់មិនអាចយកទៅប្រើប្រាស់ក្នុងគោលបំណងនេះឡើយ ]។[82]

### ៣.២.កត្តាអាជ្ញាធរមូលដ្ឋាន

សមត្ថកិច្ចមានកម្រិតរបស់អាជ្ញាធរមូលដ្ឋានក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិ គឺជាឧបសគ្គមួយក្នុងការដោះស្រាយវិបត្តិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច។ អាជ្ញាធរបានត្រឹមតែធ្វើតាមបញ្ជាពីថ្នាក់លើតែប៉ុណ្ណោះ ហើយភាគច្រើននៃអាជ្ញាធរខ្លាចបញ្ហាដែលប្រឈមឲ្យមានការដកតួនាទី។[83] ដូច្នេះហើយដែលនាំឲ្យជនជាតិដើមភាគតិចបាត់បង់ដីធ្លី ឬខកខានក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិ គឺដោយសារតែអាជ្ញាធរមូលដ្ឋានខ្វះសមត្ថកិច្ចក្នុងការដោះស្រាយនូវបញ្ហាដីធ្លីជូនសហគមន៍ជនជាតិដើមភាគតិច។

សមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន គឺជាកត្តាមួយដែលធ្វើអោយសហគមន៍ជនជាតិដើមភាគតិចបាត់បង់ដីធ្លី។ នៅក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ កាលណាអាជ្ញាមូលដ្ឋាននៅខ្វះខាតចំណេះដឹងអំពីដំណើរការក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ហូភាព ដូច្នេះអាជ្ញាធរមិនអាចបំពេញមុខងាររបស់ខ្លួនដើម្បីតំណាងឲ្យពលរដ្ឋក្នុងសហគមន៍ និងបម្រើផលប្រយោជន៍ទូទៅបានទេ។

ការផ្តល់ដីសម្បទានសេដ្ឋកិច្ចក៏ជាកត្តាដែលនាំឲ្យសហគមន៍ជនជាតិដើមភាគតិចប្រឈមនឹងការបាត់បង់ដីធ្លី [សម្បទានដីសេដ្ឋកិច្ច សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឲ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់អាជីវកម្មកសិកម្ម និង កសិ-ឧស្សាហកម្ម] ។[84] ម្យ៉ាងវិញទៀត អាជ្ញាធរមូលដ្ឋានបានផ្សំគំនិតគ្នាដោយផ្ទាល់ក្នុងការធ្វើរំលោភបំពានដល់សហគមន៍ជនជាតិដើមភាគតិចដោយការបណ្តេញពួកគេចេញពីដីធ្លីដោយបង្ខំនិងបំផ្លាញទំនុកចិត្តក្នុងការការពារដីរបស់សហគមន៍។ ក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណពីរាជរដ្ឋាភិបាលបានធ្វើការរំលោភបំពានយកដីពីសហគមន៍ដោយការចាប់យកដីនិងសមគំនិត

[82] មជ្ឈមណ្ឌលសិទ្ធិមនុស្ស " *ការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ហូភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា* ", (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, កុម្ភៈ ២០១៦), ៤៧។
[83] មជ្ឈមណ្ឌលសិទ្ធិមនុស្ស " *ការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ហូភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា* ", (ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, កុម្ភៈ ២០១៦), ៣៣។
[84] អនុក្រឹត្យស្តីពីការសម្បទានដីសេដ្ឋកិច្ច, លេខ១៤៦អនក្រ/បក, ២៧ ធ្នូ ២០០៥, មាត្រា២, នៅក្នុង ហាប់ ផល្វី, វាយឡើងវិញ, *កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្ម* (ភ្នំពេញ៖ ជោគជ័យ, ២០១៥), ៧៦២ និង ៧៦៣។

កាប់ព្រៃឈើខុសច្បាប់នៅក្នុងតំបន់ដីសម្បទានរបស់ពួកគេ និងរារាំងមិនឲ្យសហគមន៍មានលទ្ធភាពក្នុងការកំណត់ដីទៅលើដីប្រពៃណីរបស់ពួកគេ។ ការកាប់ព្រៃឈើរបស់ក្រុមហ៊ុនធ្វើឲ្យប៉ះពាល់ដល់ប្រពៃណី ទំនៀមទម្លាប់ ដូចជា ព្រៃអារក្ស ព្រៃកប់ខ្មោច ដែលជាហេតុនាំឲ្យបាត់បង់អត្តសញ្ញាណរបស់ពួកគាត់ផងដែរ។

# សេចក្តីសន្និដ្ឋាន

ការយល់ដឹងផ្នែកច្បាប់ពាក់ព័ន្ធនឹងសិទ្ធិលើដីធ្លីរបស់បងប្អូនជនជាតិដើមភាគតិច មានសារៈសំខាន់ក្នុងការការពារដី ពីការទន្ទ្រាន និងការរំលោភបំពាន។ ច្បាប់បានកំណត់ និងបែងចែកច្បាស់លាស់ពីសិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច។ តែផ្ទុយទៅវិញបច្ចុប្បន្ន ការយល់ដឹងផ្នែកច្បាប់របស់ជនជាតិដើមភាគតិចនៅមានកម្រិត ហើយខ្លះទៀតមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីដឹងអំពីសិទ្ធិប្រើប្រាស់ដី សិទ្ធិគ្រប់គ្រងដី និងនីតិវិធីក្នុងការចុះបញ្ជីដីធ្លីដើម្បីឲ្យច្បាប់ការពារដីរបស់ពួកគាត់នោះទេ។

កង្វះខាតការយល់ដឹងគតិយុត្ត គឺជាបញ្ហាប្រឈមទៅនឹងការបាត់បង់ដីធ្លីរបស់ជនជាតិដើមភាគតិច។ ការទន្ទ្រាន ការរំលោភបំពាន និងការវិនិយោគដីទៅឲ្យក្រុមហ៊ុន ក៏ជាបញ្ហាមួយដែលនាំឲ្យជនជាតិដើមភាគតិចបាត់បង់ដីធ្លីដែរ។ កាលណាជនជាតិដើមភាគតិចបាត់បង់ដីធ្លីហើយនោះវប្បធម៌ ប្រពៃណី ជំនឿ និងទំនៀមទម្លាប់របស់ពួកគាត់តាំងពីដូនតាមកក៏អាចនឹងបាត់បង់ផងដែរ ដោយសារតែ វប្បធម៌ ប្រពៃណី ជំនឿ និងទំនៀមទម្លាប់ ទាំងអស់នេះបានផ្សាភ្ជាប់ទៅនឹងដីធ្លីរបស់ពួកគាត់ ដែលមានដូចជាដីព្រៃអារក្ស ដីចម្ការវិលជុំ និងដីព្រៃកប់ខ្មោចជាដើម។

ចំណេះដឹង និងការយល់ដឹងផ្នែកច្បាប់របស់ជនជាតិដើមភាគតិចទាំងអស់ ជាផ្នែកមួយសំខាន់សម្រាប់ការរស់នៅអោយមានសុវត្ថិភាព និងមានការការពារពីច្បាប់ ហើយក៏ជាផ្នែកមួយក្នុងការអភិវឌ្ឍន៍សង្គមជាតិឲ្យមានភាពប្រសើរឡើង និងរីកចម្រើនថែមមួយកម្រិតទៀតដែរ។

# អនុសាសន៍

ការយល់ដឹងផ្នែកច្បាប់របស់ជនជាតិដើមភាគតិច ជាផ្នែកមួយសំខាន់ក្នុងការរស់នៅប្រចាំថ្ងៃ និងក៏ជាផ្នែកមួយក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ ដោយបងប្អូនជានជាតិដើមភាគតិចមួយចំនួនមិនមានការយល់ដឹងផ្នែកច្បាប់ពាក់ព័ន្ធការយកដីទៅចុះបញ្ជី ដូច្នេះហើយស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអាជ្ញាធរមានសម្ថកិច្ច គួរខំតខំប្រឹងប្រែងក្នុងការងារផ្តល់ព័ត៌មាន និងចុះណែនាំបន្ថែមដល់មូលដ្ឋានបងប្អូនជនជាតិដើមភាគតិចដើម្បីឲ្យពួកគាត់កាន់តែយល់ដឹងពីប្រព័ន្ធច្បាប់ដែលពាក់ព័ន្ធនឹងដីធ្លីរបស់សហគមន៍ ជាពិសេសមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គ្រប់ខេត្តក្រុងដែលមានជនជាតិដើមភាគតិចរស់នៅ គួរព្យាយាមបង្កើនការផ្សព្វផ្សាយព័ត៌មានអំពីនីតិវិធីនៃការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឲ្យពួកគាត់បានដឹង និងបានយល់ពីដំណើរការនៃការចុះបញ្ជីដីធ្លីរបស់ពួកគាត់ដោយមានការពារពីច្បាប់។

រាជរដ្ឋាភិបាលគួរលុបបំបាត់ និងមានវិធានការផ្លូវច្បាប់ពាក់ព័ន្ធនឹងការអនុវត្តច្បាប់របស់មន្ត្រី ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចមិនមានតម្លាភាព ឬមិនមានភាពសុក្រឹតយុត្តិធម៌ដល់ប្រជាពលរដ្ឋ និងមានការគំរាមគំហែងពីសំណាក់អ្នកមានអំណាច ឬអ្នកមានប្រាក់ទៅលើប្រជាពលរដ្ឋទន់ខ្សោយដូចជាបងប្អូនជនជាតិដើមភាគតិចជាដើម។ កាលណារាជរដ្ឋាភិបាលមានការអនុវត្តច្បាប់ដោយមានតម្លាភាព និងយុត្តិធម៌នោះប្រជាពលរដ្ឋ ជាពិសេសបងប្អូនជនជាតិដើមភាគតិចមានទំនុកចិត្តលើប្រព័ន្ធច្បាប់ និងមានការរស់នៅដោយភាពពេញចិត្ត សុវត្ថិភាព មិនមានការភ័យខ្លាចបាត់បង់ដី ឬការរំលោភបំពានពីគ្រប់មជ្ឈដ្ឋាន។

# គន្ថនិទ្ទេស


## ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច, ២៤ មេសា ២០០៩។

គោលនយោបាយជាតិស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច, ២៤ មេសា ២០០៩។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ច្បាប់ព្រៃឈើ, លេខ នស/រកម/០៨០២/០១៦, ៣១ សីហា ២០០២។

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, លេខ នស/រក/០២០៨/០០៧, ១៥ កុម្ភៈ ២០០៨។

បទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសម្ពហភាពសហគមន៍ជនជាតិដើភាគតិព្នង ភូមិពន្ទជា ឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, លេខ៨៣អនក្រ/បក, ០៩ មិថុនា ២០០៩។

## សៀវភៅនិងឯកសារផ្សេងៗ

តឹក វណ្ណារ៉ា. "ការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គ និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច". សិក្ខាសាលាថ្នាក់ជាតិ, សណ្ឋាគារហ៊ីម៉ាវ៉ារី, ២៩-៣០ មេសា ២០១៤។

ត្រឹង ងា. *អរិយធម៌ខ្មែរ*. ភ្នំពេញ៖ ១៩៧៤។

មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់*ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា*. ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ពសាស្ត្រា។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា. *ការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ពហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា*. ភ្នំពេញ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ២០១៦។

សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសម្ពហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា។

ហាប់ ផល្លី, វាយឡើងវិញ. *កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្ម*. ភ្នំពេញ៖ ជោគជ័យ, ១០១៥។

ហេង ឆ្លូញ. "ជនជាតិដើមភាគតិចជាមួយនឹងសិទ្ធិលើអចលនៈវត្ថុ." ឯកសារថតចម្លងថ្ងៃទី ០៦ កក្កដា ២០១៥។

## គេហទំព័រ

https://opendevelopmentcambodia.net/km/topics/ethnic-minorities-and-indigenous-people/
https://km.wikipedia.org/wiki/